# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់ អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT TAXATION’S PROCESS OF COLLECTING PUBLIC TAX

## ជំនាញ: គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់ អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT TAXATION’S PROCESS OF COLLECTING PUBLIC TAX

## សាស្ត្រាចារ្យណែនាំ៖ ឱម ហ៊ីន

## ជំនាញ: គណនេយ្យ

## រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទៈដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

សាស្ត្រាចារ្យណែនាំ

ឱម ហ៊ិន

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ និងពន្ធ ជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យ និងពន្ធដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតទាំងអស់គ្នាកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារការងារគណនេយ្យពន្ធតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីពីរ រហូតដល់ឆ្នាំសិក្សាទីបី។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ឆួក ចខខ្វាន់

ID: B21/1172



អ៊ី សុខកញ្ញា

ID: B21/1202



ជឹម កញ្ញា

ID: B21/119



ដែន ស្រីដាន

ID: B21/1045



យ៉េន ស្រីពៅ

ID: B21/957

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញ គណនេយ្យ៖

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ សូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថានវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ឱម ហ៊ិន** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមខ្ញុំបាទ នាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថាខ្លឹមសារសារណាក្រោមប្រធានបទ "ដំណើរការនៃការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. .............. ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ពន្ធដារ ត្រូវបានបង្កើតឡើងតាំងពីសម័យអាណានិគមនិយមបារាំងមកម្ល៉េះ តែក៏ត្រូវបានលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារការកើតឡើងនៅសង្គ្រាម (របបខ្មែរក្រហម ឬរបបប៉ុលពត) បានធ្វើឱ្យប្រជាជនជួបនូវភាពលំបាក ការបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដែលបានអនុវត្តន៍ឡើងនៅរាជធានីភ្នំពេញ និងតាមបណ្តាលខេត្តចំនួន ១០ផ្សេងទៀតដែលគេហៅថារបបម៉ៅការត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានពន្ធដារ។ នៅក្នុងឆ្នាំ២០១៣ អគ្គនាយកដ្ឋានពន្ធដារត្រូវបានកែសម្រួល និងរៀបចំរចនាសម្ព័ន្ធបន្ថែមទៀតតាមរយៈអនុក្រឹតលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលាឆ្នាំ២០១៣ ដោយបានកំណត់បញ្ជាក់យ៉ាងច្បាស់ថា អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធដែលមានប្រព័ន្ធចាត់តាំងឯកភាពទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាករបំភ្លឺសាធារណៈ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ គឺមាត្រា២៣។ ប៉ុន្តែមាត្រា២៣នេះ ត្រូវបានប្តូរទៅជាមាត្រា២៣ថ្មីដោយការធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២ ចំពោះតម្លៃសុរាមេរ័យ និងបារីដែលលក់នៅក្នុងមណ្ឌលដែនដីខេត្ត-ក្រុងត្រូវបានបានប្រមូលតាមចំនួន៣៥ លើតម្លៃសុរាមេរ័យនិងបារីដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ។ អាករបំភ្លឺសាធារណៈ ត្រូវបានកំណត់អត្រា៣% នៅក្នុងឆ្នាំ២០០២ តែក្រោយមកនៅក្នុងឆ្នាំ២០២៣ អត្រានៃអាករបំភ្លឺសាធារណៈត្រូវបានប្តូរទៅជា ៥% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលទាំងអស់ នូវសុរាមេរ័យ និងបារីក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិការថ្នាក់ក្រោមជាតិ សម្រាប់បំភ្លឺនៅព្រះរាជាណាចក្រកម្ពុជា។

កាលពីមុន អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ធ្វើការបង់ប្រាក់បន្ត និងស្នើសុំទម្រង់លិខិតប្រកាសពន្ធនៅតាមសាខាពន្ធដារខណ្ឌរៀងៗខ្លួន។ ប៉ុន្តែ ដោយមានភាពលំបាកសម្រាប់មន្ត្រីពន្ធ ក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជា បានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយធ្វើការផ្លាស់ប្តូរនីតិវិធីក្នុងការប្រមូលអាករបំភ្លឺសាធារណៈ និងការដាក់លិខិតប្រកាសផ្សេងៗឱ្យមានលក្ខណៈទំនើបនិងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធ ........ ii

សេចក្ដីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## រំលឹកទ្រឹស្ដី

២.១ លក្ខណៈទូទៅនៃអាករបំភ្លឺសាធារណៈ ........ ៤

២.២ នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

    ២.២.១ និយមន័យពន្ធ ........ ៥

    ២.២.២ ប្រវត្តិពន្ធ ........ ៦

    ២.២.៣ ប្រភេទនៃពន្ធ ........ ៧

២.៣ ការប្រមូលអាករបំភ្លឺសាធារណៈផ្ដល់ផលប្រយោជន៍ចំពោះសង្គមជាតិ ........ ៨

    ២.៣.១ និយមន័យសង្គម ........ ៨

    ២.៣.២ ទ្រឹស្ដីនៃសង្គម ........ ៨

    ២.៣.៣ ប្រភេទនៃសង្គម ........ ៩

## ជំពូកទី៣

## លទ្ធផលនៃការសិក្សាស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១១
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ........ ១៥
ក. ចក្ខុវិស័យ ........ ១៥
ខ. បេសកកម្ម ........ ១៥
គ. គោលដៅ........ ១៥
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៦
ក. រចនាសម្ព័ន្ធគ្រប់គ្រង ........ ១៦
ខ. តួនាទី និងភារកិច្ច........ ១៧
៣.២ នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៧
៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ........ ១៧
៣.២.២ បុគ្គលជាប់អាករ........ ១៧
៣.២.៣ ផលិតផលជាប់អាករ ........ ១៨
៣.២.៤ ការគណនាអាករបំភ្លឺសាធារណៈ ........ ១៩
៣.២.៥ នីតិវិធីការប្រមូលអាករបំភ្លឺសាធារណៈ ........ ២១
៣.២.៦ ការទទួលលិខិតប្រកាស ........២៣
៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ២៥

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........ ២៧
៤.២ ការវិភាគលើចំណុចខ្សោយ ........ ២៨

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........ ២៩
៥.២ ការផ្តល់អនុសាសន៍ ........ ៣០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសនីមួយៗនៅក្នុងសកលលោកទាំងអស់ គឺតែងតែមានការដឹកនាំការអភិវឌ្ឍន៍ និងភាពជឿនលឿនខុសៗគ្នាដោយសារតែប្រទេសអភិវឌ្ឍន៍ ហើយប្រទេសមួយចំនួនទៀតកំពុងអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាជាប្រទេសតូចមួយដែលទទួលរងគ្រោះដោយសារសង្គ្រាម និងស្ថិតនៅក្រោមអាណានិគមនិយមបារាំងដែលបន្សល់ទុកនូវប្រជាជនប្រមាណ១៦លាននាក់ ហើយក៏ជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ក្នុងវិស័យសេដ្ឋកិច្ច ទោះបីជាប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍន៍ក្តីតែភាពរីកចម្រើននៅក្នុងវិស័យជាច្រើនដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យសំណង់ និងអចលនទ្រព្យបានធ្វើឱ្យប្រទេសកម្ពុជាមានការលូតលាស់ទៅមុខយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់។

ជាក់ស្តែង ដំណើរការនៃការប្រមូលពន្ធនៅកម្ពុជា គ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងតាមដានទៅលើចំណូល និងចំណាយរបស់រាជរដ្ឋាភិបាលតាមរយៈការប្រមូលពន្ធពីអ្នកជាប់ពន្ធរបស់សហគ្រាសតូច ធំជាដើម។ ការប្រមូលពន្ធទាំងអស់នេះរួមមាន ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ពន្ធប៉ាតង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា ពន្ធលើផលរបរ ពន្ធលើការស្នាក់នៅ ពន្ធដីធ្លី ផ្ទាំងផ្សព្វផ្សាយអាករបំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន ពន្ធដីធ្លីមិនបានប្រើប្រាស់ ពន្ធលើយានយន្តគ្រប់ប្រភេទ ពន្ធលើមធ្យោបាយដឹកជញ្ជូន ។ ដូច្នេះ ពន្ធដារមានសារៈសំខាន់ណាស់ក្នុងការបង្កើតថវិកាជូនជាតិ ហេតុនេះហើយ អ្នកជាប់ពន្ធទាំងអស់គួរគប្បីយល់ដឹងពីការបង់ពន្ធ និងគោរពតាមច្បាប់ដែរបានចែងរបស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានត្រឹមត្រូវ។ ប្រសិនបើ សហគ្រិនទាំងអស់នោះមិនអនុវត្តន៍តាមច្បាប់របស់អគ្គនាយកដ្ឋានពន្ធដារទេ នោះអាចធ្វើឱ្យសេដ្ឋកិច្ចជាតិមានការថយចុះជាក់ជាមិនខានឡើយ អ្នកជាប់ពន្ធត្រូវយល់ដឹងច្បាស់ពីសារៈសំខាន់របស់ពន្ធដារ ដើម្បីកសាងសេដ្ឋកិច្ចជាតិឱ្យកាន់តែមានការរីកចម្រើនឡើង និងជួយធ្វើឱ្យវិស័យមួយនេះកាន់តែមានសក្តានុពលរីកសុះសាយពាសពេញផ្ទៃប្រទេស។

ដោយផ្អែកទៅលើហេតុផលទាំងអស់នេះហើយ ទើបក្រុមនាងខ្ញុំទាំងអស់គ្នាសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី «**ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**» យកមកស្រាវជ្រាវចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ពន្ធដារដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកបង្កើនថវិការជាតិសម្រាប់ធានាសេចក្តីត្រូវការ និងចំណាយសាធារណៈដែលកើតឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ដើម្បីជួយសម្រួលលើបន្ទុកចំណាយទាំងអស់នេះ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតអាករមួយប្រភេទហៅថា «**អាករសម្រាប់បំភ្លឺសាធារណៈ**»។ ដូច្នេះ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ទើបក្រុមយើងខ្ញុំ មានសំណួរដើម្បីចោទសួរទៅលើប្រធានបទដូចខាងក្រោម៖

១. តើនីតិវិធីនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

២. តើការប្រមូលអាករបំភ្លឺសាធារណៈផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញពីយន្តការនៃការគណនាអាករបំភ្លឺសាធារណៈ និងអត្ថប្រយោជន៍បន្ថែមឱ្យអ្នកដែលជាប់ពន្ធទាំងអស់យល់ដឹងឱ្យបានច្បាស់ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការប្រកាសពន្ធ និងមិនបាត់បង់ចំណូលថវិការជាតិផងដែរ ដោយផ្តល់ទៅលើ៖

- ប្រវត្តិនៃអគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជា
- គោលនយោបាយបេសកកម្ម និងទស្សនៈវិស័យរបស់ពន្ធដារ
- តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះគឺសិក្សាទៅលើ «ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ» នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្តីពីសារពើពន្ធ ពន្ធត្រូវបានកំណត់ឡើងយូរណាស់មកហើយ ដោយមានពេលវេលាកំណត់ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពី "ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ" ទើបក្រុមនាងខ្ញុំ ធ្វើការស្រាវជ្រាវតែក្នុងឆ្នាំ២០២៣ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើឱ្យដំណើរការនៃការសរសេរសារណាទៅលើប្រធានបទ "ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ" ឱ្យបានជោគជ័យក្រុមនាងខ្ញុំធ្វើការស្រាវជ្រាវដូចខាងក្រោម។

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង គឺជាការប្រមូលទិន្នន័យតាមរយៈការចុះសាកសួរដោយផ្ទាល់ពីមន្ត្រី និងអ្នកគ្រប់គ្រងនៃអគ្គនាយកដ្ឋានពន្ធដារ។ ដោយឯកសារ ដែលក្រុមនាងខ្ញុំបានប្រមូលត្រូវបានរៀបចំតាមលំដាប់លំដោយជាផ្នែកៗទៅតាមខ្លឹមសារអត្ថន័យនៃឯកសារនីមួយៗ ដោយឡែកពីគ្នាដើម្បីងាយស្រួលក្នុងការសរសេរកិច្ចការស្រាវជ្រាវឱ្យកាន់តែប្រសើរឡើង។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺជាការប្រមូលទិន្នន័យតាមរយៈការស្រាវជ្រាវនៅបណ្ណាល័យនានា និក្ខេបបទសិស្សច្បង និងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារជាដើម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនូវភាពរីកចម្រើនដល់ក្រុមនាងខ្ញុំជាច្រើនក្នុង ការផ្លាស់ប្តូរពួកយើងឱ្យយល់ដឹងពីសកម្មភាពក្នុងសង្គមការទំនាក់ទំនងនិងប្រតិបត្តិការមួយចំនួននៅក្នុងពេលបច្ចុប្បន្ននេះ។

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺ ផ្តល់នូវចំណេះដឹងដល់ក្រុមនាងខ្ញុំដូចជា៖

- មានការទំនាក់ទំនងប្រាស្រ័យទាក់ទងគ្នា និងចូលរួមក្នុងសង្គមយល់ដឹងពីវិធីសាស្ត្រស្រាវជ្រាវ និងនីតិវិធីប្រមូលទិន្នន័យ
- មានបទពិសោធន៍ក្នុងការបង្ហាត់បង្រៀន និងការដោះស្រាយបញ្ហានានា
- បង្កើនចំណេះដឹងបន្ថែមទៅលើការសិក្សាស្រាវជ្រាវ

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធ នៃការស្រាវជ្រាវធ្វើឡើង ដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់នៅចំណុចនីមួយៗ និងបានធ្វើឡើងដោយការរាប់បញ្ចូលចំណុច ដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ។ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន ការផ្តល់អនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមកយើងខ្ញុំក៏បានបែងចែកជា៥ជំពូកដែលរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖** (**សេចក្តីផ្តើម**) បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** (**រំលឹកទ្រឹស្តី**) បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖** (**លទ្ធផលនៃការស្រាវជ្រាវ**) បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ គោលនយោបាយ ទស្សនៈវិស័យ និងបេសកកម្មគោលដៅរបស់អគ្គនាយកដ្ឋានពន្ធដារ។

**ជំពូកទី៤៖** (**ការវិភាគពីចំណុចខ្លាំងនិងចំណុចខ្សោយ**) វិភាគ និងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖** (**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**) សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# រំលឹកត្រីស្តី

# ជំពូកទី២

# ការប្រមូលអាករបំភ្លឺសាធារណៈ

## ២.១ លក្ខណៈទូទៅនៃអាករបំភ្លឺសាធារណៈ

### ២.១.១ និយមន័យអាករ

**អាករ** គឺសំដៅដល់អាករសម្រាប់បំភ្លឺសាធារណៈ។

**អាករ** គឺសំដៅដល់កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវបង់ (សាច់ប្រាក់ឬវត្ថុ) ជូនរដ្ឋទៅតាមច្បាប់កំណត់ដោយប្រយោល[1]។

**អាករបំភ្លឺសាធារណៈ (Public light tax)** គឺជាប្រភេទពន្ធប្រយោលដែលគិតទៅលើតម្លៃស្រា និងបារីដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ ហើយដែលត្រូវកាត់ទុកដោយអ្នកលក់ ដើម្បីបង់ជូនរដ្ឋជាបន្តនាពេលក្រោយទៀត[2]។

**អាករបំភ្លឺសាធារណៈ (Tax on public lighting)** គឺជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់នៃការផ្គត់ផ្គង់សុរាមេរ័យ (គ្រឿងស្រវឹង) និងបារីបន្ទាប់ពីរបាននាំចូលឬផលិតផលជាប់អាករក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីជាប្រយោជន៍ដល់ថវិការក្រោមជាតិសម្រាប់បំភ្លឺសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា[3]។

### ២.១.២ ប្រវត្តិនៃអាករ

នៅក្នុងឆ្នាំ១៩៥៤ ប្រទេសបារាំងបានក្លាយជាប្រទេសដំបូងគេ ដែលណែនាំកាត់បន្ថយទម្រង់នៃពន្ធលើតម្លៃបន្ថែម។ ទោះជាយ៉ាងណា ការពិនិត្យឡើងវិញនៃបណ្ដាប្រទេស OECD ក្នុងឆ្នាំ១៩៦៧ បានបង្កើតឡើងភាគច្រើនបំផុត។ ប្រទេសនានា នូវតែប្រើប្រាស់ពន្ធលើការលក់ដំណាក់កាលតែមួយនៅកម្រិតលក់ដុំ ឬលក់រាយ។ កំឡុងពេលចុងទសវត្សរ៍ឆ្នាំ១៩៦០ និងដើមទសវត្សរ៍ឆ្នាំ១៩៧០ សមាជិកមួយចំនួនផ្សេងទៀតសំណើររបស់សហគមន៍អឺរ៉ុប បានអនុម័តពន្ធលើតម្លៃបន្ថែមហើយនៅឆ្នាំ១៩៧៣ ប្រទេសចំនួន១៣ OECD ត្រូវបានដំណើរការក្នុង VAT[4]។

នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ លំដាប់នៃពន្ធទូទៅកំណែទម្រង់ដោយបណ្ដាប្រទេស OECD នាំឱ្យមានការរីករាលដាលពន្ធលើតម្លៃបន្ថែមនៅអឺរ៉ុបជាមួយនូវវែលសេឡង់ កាណាដា និងជប៉ុនទាំងអស់ណែនាំពន្ធលើតម្លៃបន្ថែមរួមជាមួយនឹងថ្មីៗ។ ប្រទេសអេស្បាញ ព័រទុយហ្គាល់ និងក្រិចចាប់តាំងពីពេលនោះមកភាគច្រើននៃអតីតរដ្ឋសង្គមនិយមឥឡូវនេះមានអាករលើតម្លៃបន្ថែម ឧ. រុស្ស៊ី ប៉ូឡូញ ឃ្លានប៉ុល-garia និងសាធារណៈរដ្ឋឆេក និងស្លូវ៉ាគី។ Australia បានណែនាំពន្ធលើតម្លៃបន្ថែមរបស់ពួកគេនៅឆ្នាំ២០០០។

នៅឆ្នាំ១៩៨៦ នូវែសេឡង់បានបង្កើតកំណែសាមញ្ញមួយ។ អាករលើតម្លៃបន្ថែមអឺរ៉ុបជាមួយនឹងអត្រាតែមួយ និងតិចតួចបំផុតការបញ្ចេញចោល។ នូវែសេឡង់បានយកឈ្មោះ «ទំនិញ និងពន្ធលើសេវាកម្ម» (GST) ជាជាងអាករលើតម្លៃបន្ថែម ហើយនេះជាបន្តបន្ទាប់ធ្លាក់ចុះដោយកាណាដា និងអូស្ត្រាលី[5]។

---

[1] https://www.facebook.com/share/p/RcVAXhNGmSzFoPwi/?mibextid=2JQ9oc
[2] https://www.khsearch.com/qna/28554
[3] https://camnewsna.blogspot.com/2018/07/blog-post.html
[4] https://business-cambodia.com/articles/tax-16-in-cambodia-you-should-to-know
[5] https://sufio.com/blog/brief-history-of-vat/

### ២.១.៣ ប្រភេទនៃពន្ធអាករ

**១. អាករលើតម្លៃបន្ថែម (VAT)** ជាប្រភេទពន្ធប្រយោល ដែលរដ្ឋដកហូតប្រយោលពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់ក្នុងបុគ្គលជាប់អាករ។ អត្រា 0% សម្រាប់ការនាំចេញ ឬផ្គត់ផ្គង់ក្រៅកម្ពុជា និងអត្រា១០% សម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក។ VAT ដកហូតនៅពេលចេញ Invoice, Debit Note and Credit Note។

**VAT** គឺដកហូតពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់បុគ្គលជាប់អាករ[6]។

**អាករលើតម្លៃបន្ថែម** គឺជាអាករកំណត់ទៅលើការចំណាយទិញរបស់អ្នកប្រើប្រាស់ អាករនេះត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល។ ការប្រកបអាជីវកម្មភាគច្រើនទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវា[7]។

**អាករលើតម្លៃបន្ថែម** គឺជាប្រភេទពន្ធប្រយោល ដែលរដ្ឋដកហូតប្រយោលពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់ ក្នុងបុគ្គលជាប់អាករ ហើយពន្ធអាករលើតម្លៃបន្ថែមត្រូវបានកំណត់អត្រាពន្ធ១០%។

**២. អាករលើការស្នាក់នៅ** គឺជាប្រភេទពន្ធប្រយោលដែលគិតលើតម្លៃសរុបនៃការជួលកន្លែងស្នាក់នៅ ដែលអ្នកប្រើប្រាស់សេវាស្នាក់នៅជាប់កាតព្វកិច្ចត្រូវបង់ និងដែលទទួលកាត់ទុកដោយអ្នកផ្គត់ផ្គង់ ដើម្បីបង់ជូនរដ្ឋជាបន្តនាពេលក្រោយទៀត។

**អាករស្នាក់នៅ (Accommodation Tax)** គឺត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារដែលជាប់ពន្ធក្នុងរបបស្វ័យប្រកាស សម្រាប់ជាគុណប្រយោជន៍ថវិការថ្នាក់ក្រោមជាតិ លើកលែងតែសកម្មភាពដូចជាការប្រជុំ ឬសិក្ខាសាលាជាដើម[8]។

## ២.២ ការកំណត់គោលនយោបាយ និងនីតិវិធីការប្រមូលអាករបំភ្លឺសាធារណៈ

### ២.២.១ និយមន័យពន្ធ

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាព ដែលកំណត់ដោយច្បាប់។ យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ១៩៩៧ ពន្ធសំដៅដល់ពន្ធផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ (Taxpayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធ ដោយប្រយោល ( មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ)។ ការប្រមូលពន្ធនេះ គឺជាការយកតាមតម្លៃ ទំនិញ ឬសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ[9]។

**ពន្ធ** គឺមានលក្ខណៈបង្ខំហើយមិនសងឲ្យវិញផ្ទាល់ឡើយ ប៉ុន្តែ និងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលនយោបាយប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្មសេវាកម្ម ដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវចំពោះមុខច្បាប់ក្នុងការអនុវត្ត ឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយណា ដែលបានកំណត់និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបានមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល។

**ពន្ធ** គឺជារូបធាតុនៃការប្រមូលចំណូល ដែលភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយរបស់រដ្ឋាភិបាលដែលក្រិត្យច្បាប់ជាកំណត់។

---

[6] Sharing Knowledge
[7] https://www.facebook.com/share/v/e2cs21LuGjUj36ts/?mibextid=oFDknk
[8] https://www.facebook.com/660085454171887/posts
[9] https://www.facebook.com/ibmsaccounting/posts

**ពន្ធ** គឺជារូបភាពនៃការបែងចែកឡើងវិញនូវចំណូលជាតិ ដែលរដ្ឋាភិបាលប្រើប្រាស់ ដើម្បីប្រមូលចំណូលមួយផ្នែក ពីគ្រប់សមាសភាពសេដ្ឋកិច្ចក្នុងការផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយ និងជាវិភាគទានទាំងរូបវន្តបុគ្គល និងនីតិបុគ្គល[10]។

**ពន្ធ** គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវបង់ជូនរដ្ឋទៅតាមច្បាប់កំណត់។ រដ្ឋអាចប្រើប្រាស់មធ្យោបាយពន្ធ ដើម្បីលើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ចណាដែលរដ្ឋយល់ថាគួរលើកស្ទួយ និងជម្រុញដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងផលប្រយោជន៍ប្រជាជនរបស់ប្រទេសខ្លួន[11]។

**ពន្ធ** គឺជាពន្ធបន្ថែមអាករ កម្រៃ ឬបន្ទុកផ្សេងទៀតដែលយកលើទំនិញស្របតាមបញ្ញត្តិណាមួយនៃច្បាប់នេះ ឬច្បាប់និងបទប្បញ្ញត្តិផ្សេងទៀតដែលអនុវត្តនិងគ្រប់គ្រងដោយគយ[12]។

**ពន្ធ** គឺជាអ្វីៗដែលរដ្ឋធ្វើការកំណត់ប្រមូលមកពីរាស្ត្រ ដើម្បីនាំមកប្រើប្រាស់ជាប្រយោជន៍ដល់សង្គមជាតិ ដោយមិនចំពោះបុគ្គលណាមួយឡើយរួមទាំងអ្នកជាប់ពន្ធផងដែរ។

**ពន្ធ** សំដៅដល់ពន្ធអាករទាំងឡាយ (ពន្ធផ្ទាល់ និងពន្ធប្រយោល)[13]។

**ពន្ធ** គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិការជាតិ។

**២.២.២ ប្រវត្តិនៃពន្ធ**

ពន្ធអាចមានភាពស្មុគស្មាញ ហើយការយល់ដឹងពួកគេទាមទារឱ្យកាន់តែស៊ីជម្រៅជាងការដឹងពីលេខកូដពន្ធបច្ចុប្បន្ន និងរបៀបដែលវាប៉ះពាល់ដល់តវិយាបទ។ ប្រវត្តិនៃការយកពន្ធ មូលហេតុដែលវាត្រូវបានប្រើប្រាស់ និងរបៀបដែលវាមានឥទ្ធិពលលើសង្គមពីមុន អាចជួយយើងឱ្យយល់អំពីអត្ថប្រយោជន៍ និងផលវិបាកដែលអាចកើតមានចំពោះពន្ធបច្ចុប្បន្ន និងដែលបានស្នើឡើង។ ប្រវត្តិសាស្ត្រនេះក៏អាចជួយអ្នកបង្កើតគោលនយោបាយព្រាងច្បាប់បានល្អប្រសើរដោយផ្អែកលើលទ្ធផល និងគំរូពីអតីតកាល[14]។ លេខកូដពន្ធនាពេលបច្ចុប្បន្ននេះមានលក្ខណៈទូលំទូលាយ និងផ្លាស់ប្តូរជានិច្ច ប៉ុន្តែប្រភេទពន្ធមូលដ្ឋានជាច្រើនរបស់រដ្ឋាភិបាលពឹងផ្អែកលើសព្វថ្ងៃនេះ រួមទាំងពន្ធលើការលក់ ពន្ធលើអចលនទ្រព្យ និងពន្ធអចលនទ្រព្យមានតាំងពីសម័យដើម។ ភាគច្រើននៃការចាប់ផ្តើមនៃប្រវត្តិសាស្ត្ររបស់អាមេរិកផ្តោតលើការយកពន្ធ[15]។ ដើមឡើយ អាមេរិកមិនមានប្រភពចំណូលទំនើបដ៏ធំបំផុតរបស់ខ្លួនទេ ពោលគឺពន្ធលើប្រាក់ចំណូល។ លើសពីនេះទៀត អាណានិគមនិយម និងពាណិជ្ជករដើមជាច្រើននៅសតវត្សទី 17 ត្រូវបានលើកលែងពីការប្រមូលពន្ធពីប្រទេសមហាអំណាចធំៗរបស់ពួកគេក្នុងរយៈពេលពីរបីឆ្នាំ ហើយខ្លះទៀតរហូតដល់ ២០ឆ្នាំ។ អាណានិគមអាមេរិកបានយកពន្ធលើអចលនទ្រព្យ ពន្ធគយ ពន្ធលើការស្ទង់មតិ និងទម្រង់ដើមួយចំនួននៃពន្ធលើប្រាក់ចំណូលទោះបីជាអត្រា និងបន្ទុកគឺតិចជាងសមភាគីរបស់ពួកគេនៅក្នុងចក្រភពអង់គ្លេសក៏ដោយ។ ខណៈពេលដែលរដ្ឋាភិបាលអាមេរិកកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ រដ្ឋាភិបាលអង់គ្លេសបានប្រឈមនឹងបំណុលពីសង្គ្រាម

[10] https://www.linkedin.com/pulse-sarith-khem
[11] https://www.facebook.com/707252746026143
[12] https://www.khsearch.com/qna/31015
[13] https://www.youtube.com/watch?v=svJcBEBDmR0
[14] https://newint.org/features/2008/10/01/tax-history
[15] https://www.accountancyage.com/2021/01/26/a-brief-history-of-taxation/?amp=1

ជាច្រើននៅទូទាំងពិភពលោក[16]។ ភាគច្រើននៃការចាប់ផ្តើម នៃប្រវត្តិសាស្ត្ររបស់អាមេរិក ផ្តោតលើការយកពន្ធ។ ដើមឡើយ អាមេរិកមិនមានប្រភពចំណូលទំនើបដ៏ធំបំផុតរបស់ខ្លួនទេ ពោលគឺពន្ធលើប្រាក់ចំណូល។ លើសពីនេះទៀត អាណានិគមនិយម និងពាណិជ្ជករដើមជាច្រើននៅសតវត្សទី17 ត្រូវបានលើកលែងពីការប្រមូលពន្ធពីប្រទេសមេរបស់ពួកគេ ក្នុងរយៈពេលពីរបីឆ្នាំ ហើយខ្លះទៀតរហូតដល់ 20 ឆ្នាំ។ ប្រហែលជា 5,000 ឆ្នាំមុន យើងឃើញកំណត់ត្រាដំបូងនៃការយកពន្ធនៅក្នុងប្រទេសអេហ្ស៊ីបបុរាណ ដែលព្រះចៅផារ៉ោនបានប្រមូលពន្ធស្មើនឹង 20 ភាគរយនៃការប្រមូលផលគ្រាប់ធញ្ញជាតិទាំងអស់។ នៅពេលនោះប្រទេសអេហ្ស៊ីបមិនមានលុយកាក់ទេ ដូច្នេះ គ្រាប់ធញ្ញជាតិតំណាងឱ្យឃ្លាំងនៃតម្លៃជាក់ស្តែង ដែលអាចប្រមូលបានជួញដូរ និងចែកចាយឡើងវិញបានយ៉ាងងាយស្រួលនៅទូទាំងសង្គម។ ដូចទៅនឹងការច្នៃប្រឌិតទំនើបៗជាច្រើនដែរ ជនជាតិក្រិចមានទំនួលខុសត្រូវក្នុងការទទួលយកគំនិតនៃការយកពន្ធ ហើយផ្សព្វផ្សាយវាពាសពេញប្រទេសអភិវឌ្ឍន៍ នៅពេលដែលពួកគេបានពង្រីកអាណាចក្រ និងអរិយធម៌របស់ពួកគេបានរីកចំរើន[17]។

### ២.២.៣ ប្រភេទនៃពន្ធ

**ពន្ធ** គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋសម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការនៃវិស័យសាធារណៈផ្សេងៗ។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធចំនួន ១៦ប្រភេទដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

1. ពន្ធលើប្រាក់ចំណូល
2. ពន្ធអប្បបរមា
3. ពន្ធកាត់ទុក
4. ពន្ធលើឈ្នួលផ្ទះ និងដី
5. ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម
6. ពន្ធតែមប្រើសារពើពន្ធ (ស្លាកយីហោ និងផ្សព្វផ្សាយពាណិជ្ជកម្ម)
7. ពន្ធប៉ាតង់
8. ពន្ធប្រថាប់ត្រា
9. ពន្ធលើដីធ្លីមិនបានប្រើប្រាស់
10. ពន្ធលើអចលនទ្រព្យ
11. ពន្ធលើចំណេញមូលធន
12. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
13. អាករលើតម្លៃបន្ថែម
14. អាករលើការស្នាក់នៅ

[16] https://academic.oup.com/edited-volume/52507/chapter-abstract/422125371?redirectedFrom=fulltext
[17] https://www.worldtaxation.com/uncategorized/history-of-taxation.html

15. អាករបំភ្លឺសាធារណៈ

16. អាករពិសេស[18]។

## ២.៣ ផលប្រយោជន៍ចំពោះសង្គមជាតិ

### ២.៣.១ និយមន័យសង្គម

**សង្គម** គឺមានអត្ថន័យនៃពាក្យមាននៅក្នុងការទំនាក់ទំនងរវាងមនុស្ស និងមនុស្សពេលគឺនៅក្នុងរចនាសម្ព័ន្ធសង្គម។ គំនិតនេះគឺប្រវត្តិសាស្ត្រស្ថិរភាព និងការតភ្ជាប់ប្រព័ន្ធជាតុគ្នាទំនាក់ទំនងរវាងបុគ្គល និងសង្គម និងក្រុមផ្សេងទៀត។

**សង្គមនិយម** គឺជាអង្គសេដ្ឋកិច្ចរបស់សង្គម ដែលសង្គមនីមួយៗមានសិទ្ធិទៅលើមធ្យោបាយរួមដែលត្រួតពិនិត្យដោយតំណាងរបស់សង្គម និងជាអ្នកទទួលខុសត្រូវចំពោះសង្គម ហើយសមាជិកម្នាក់នៃសង្គមមានសិទ្ធិទទួលផលប្រយោជន៍ពីមូលដ្ឋាននៃផលិតកម្មរបស់សង្គម[19]។

**លោក Encyclopedia Britannica** បានឱ្យនិយមន័យសង្គមនិយម ថាជាគោលបំណងរក្សាសន្តិសុខតាមរយៈអំពើនៃរដ្ឋអំណាចប្រជាធិបតេយ្យមជ្ឈឹម ដែលមានលក្ខណៈប្រសើរក្នុងការបែងចែកឱ្យក្រោមបង្គាប់ទទួលបាននូវផលិតផលទ្រព្យសម្បត្តិដែលគេផលិតបានស្មើៗគ្នា[20]។

**សង្គម** គឺសំដៅយកធម្មជាតិមនុស្សរស់រួមគ្នា មានទីលំនៅ មានមុខរបររកស៊ី មានរបៀបបែបបទរស់នៅទាក់ទងគ្នាក្នុងស្រុកដែរជារដ្ឋ[21]។

**សង្គម** គឺជាការជួបជុំគ្នា ការប្រជុំគ្នា ការរាប់រកគ្នា ការប្រមូលរួបរួមផ្តុំមនុស្សឬសត្វ៖ សង្គមមនុស្ស និងសង្គមសត្វ[22]។

**សង្គមកិច្ច** គឺកិច្ចការក្នុងសង្គម ឬរបស់សង្គម កិច្ចការដែលធ្វើឡើងដើម្បីជួយឃើតយោងសង្គមមនុស្សឱ្យបានសុខចម្រើន។

**សង្គមប្រជាជាតិ** គឺជាអង្គការអន្តរជាតិដែលបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី១[23]។

### ២.៣.២ ទ្រឹស្តីនៃសង្គម

**សង្គម** គឺជាក្របខណ្ឌវិភាគ ឬគំរូដែលត្រូវបានប្រើប្រាស់ដើម្បីសិក្សា និងបកស្រាយបាតុភូតសង្គម។ ឧបករណ៍ដែលប្រើប្រាស់ដោយអ្នកវិទ្យាសាស្ត្រសង្គម។ ទ្រឹស្តីសង្គមទាក់ទងនឹងការជជែកវែកញែកជាប្រវត្តិសាស្ត្រលើសុពលភាព និងភាពជឿជាក់នៃវិធីសាស្ត្រផ្សេងៗគ្នា (ឧទាហរណ៍ Positive និង antipositivism) ភាពសំខាន់នៃរចនាសម្ព័ន្ធ ឬភ្នាក់ងារក៏ដូចជាទំនាក់ទំនងរវាងភាពចាំបាច់ និងភាពចាំបាច់។ ទ្រឹស្តីសង្គមក្នុងលក្ខខណ្ឌក្រៅផ្លូវការ ឬភាពជាអ្នកនិពន្ធដែលផ្អែកលើការសិក្សាសង្គម និងវិទ្យាសាស្ត្រនយោបាយអាចត្រូវបាន

[18] https://business-cambodia.com/articles/tax-16-in-cambodia-you-should-to-know
[19] https://www.khsearch.com/qna/13592
[20] https://www.khsearch.com/qna/8646
[21] https://www.khsearch.com/qna/13409
[22] https://glosbe.com/km/km/%E1%9E%9F%E1%9E%84%E1%9F%92%E1%9E%82%E1%9E%98
[23] https://www.khsearch.com/qna/8646

គេហៅថា «ការរិះគន់សង្គម» ឬ «ការអត្ថាធិប្បាយសង្គម» ឬ «ការរិះគន់វប្បធម៌» ហើយអាចត្រូវបានផ្សារភ្ជាប់ទាំងអស់ជាមួយនឹងអាហារូបករណ៍ វប្បធម៌ និងអក្សរសាស្ត្រផ្លូវការ។ ក៏ដូចជាទម្រង់នៃការសរសេរដែលមិនមែនជាការសិក្សា ឬសារព័ត៌មានផ្សេងទៀត។

**សង្គម** តាមនិយមន័យត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យមានភាពខុសគ្នា និងទូទៅក្នុងចំណោមប្រភេទផ្សេងៗនៃសង្គម និងដើម្បីវិភាគភាពទំនើបដូចដែលវាបានលេចឡើងក្នុងប៉ុន្មានសតវត្សកន្លងមកនេះ។ សង្គមដូចដែលវាត្រូវបានគេទទួលស្គាល់នាពេលបច្ចុប្បន្ននេះបានលេចចេញនៅសតវត្សទី២០ ជាវិស័យដាច់ដោយឡែកមួយ ហើយភាគច្រើនត្រូវបានសមមូលជាមួយនឹងអាកប្បកិរិយានៃការរិះគន់ និងបំណងប្រាថ្នាសម្រាប់ចំណេះដឹងតាមរយៈវិធីសាស្ត្រក្រោយនៃការរកឃើញជាជាងអតិភាពវិធីសាស្ត្រប្រពៃណី។ គំនិតនៃសង្គមផ្តល់នូវទ្រឹស្តីទូទៅដើម្បីពន្យល់ពីសកម្មភាព និងអាកប្បកិរិយារបស់សង្គមទាំងមូល ដោយរួមមានបញ្ចូលនូវគំនិត សង្គមវិទ្យា នយោបាយ និងទស្សនៈវិជ្ជា។

**សង្គមបុរាណ** ជាទូទៅត្រូវបានបង្ហាញតាមទស្សនៈនៃទស្សនៈវិជ្ជាលោកខាងលិច ហើយជារឿយៗត្រូវបានចាត់ទុកថាជា Eurocentric ។ ការស្ថាបនាទ្រឹស្តីយោងទៅតាម The Blackwell Encyclopedia of sociology គឺជាឧបករណ៍មួយ៖ «គោលដៅរបស់ពួកគេគឺដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទងដ៏ត្រឹមត្រូវ ការធ្វើតេស្តយ៉ាងម៉ត់ចត់ ភាពត្រឹមត្រូវខ្ពស់ និងការអនុវត្តន៍យ៉ាងទូលំទូលាយ»។ ពួកគេរួមមានដូចជា៖ អវត្តមាននៃភាពផ្ទុយគ្នា អវត្តមាននៃភាពមិនច្បាស់លាស់ អរូបី ភាពទូទៅ ភាពជាក់លាក់ ភាពចម្រុះ និងលក្ខខណ្ឌ។ ដូច្នេះទ្រឹស្តីសង្គមមានពាក្យសេចក្តីថ្លែងការណ៍ អំណះអំណាង និងលក្ខខណ្ឌវិសាលភាព[24]។

### ២.៣.៣ ប្រភេទនៃសង្គម

ខាងក្រោមនេះ គឺជាការចាប់អារម្មណ៍ទៅលើទំហំនៃសង្គមវិជ្ជា ដែលត្រូវបានរកឃើញតាមការស្វែងយល់បន្ថែមតាមរយៈការស្រាវជ្រាវលើផ្នែកនីមួយៗនៃបាតុភូតសង្គម។ ប្រភេទទាំងអស់នេះត្រូវបានបែងចែកជាក្រុមដូចខាងក្រោម៖

**១. សណ្ឋាណសាស្ត្រសង្គម៖** ផ្នែកនៃសង្គមវិជ្ជាដែលរួមមានកម្មវត្ថុទាំងឡាយជាមូលដ្ឋាននៃភូមិសាស្ត្រសង្គមដូចជា ប្រជារាស្ត្រតាមតំបន់ ទំហំនៃដងស៊ីតេ របាយប្រជាជន...។ ក្នុងចំណុចនេះត្រូវបានបែងចែកជាពីរគឺ៖

- វិភាគទៅលើទំហំ និងគុណភាពនៃប្រជារាស្ត្រ ព្រមទាំងឥទ្ធិពលដែលមានទៅលើគុណភាពនៃទំនាក់ទំនងសង្គម និងទំនាក់ទំនងក្រុមមនុស្ស។
- សិក្សាអំពីរចនាសម្ព័ន្ធសង្គម ឬពន្យល់នូវទម្រង់សំខាន់ៗនៃក្រុមមនុស្ស និងស្ថាប័នទាំងឡាយព្រមទាំងមានការបែងចែកលំដាប់ថ្នាក់ផងដែរ។

**២. សិរីសង្គម៖** ជាផ្នែកសង្គមវិជ្ជាទាំងឡាយដែលរួមមានកម្មវត្ថុសិក្សាដោយឡែកក្នុងវិទ្យាសាស្ត្រសង្គមមានដូចជា សាសនា សេដ្ឋកិច្ច ភាសា សីលធម៌ ច្បាប់...។ សាសនា និងសេដ្ឋកិច្ច សីលធម៌ និងភាសាត្រូវបាន

[24] https://en.m.wikipedia.org/wiki/Social_theory

លើកយកមកសិក្សាតាមរយៈសង្គមវិជ្ជា សាសនា សង្គមវិជ្ជាជីវភាពសេដ្ឋកិច្ច សង្គមវិជ្ជាសីលធម៌និងសង្គមវិជ្ជាភាសាដែលជាផ្នែកពិសេសនៃសង្គមវិជ្ជា។

**៣. សង្គមវិជ្ជាទូទៅ** ៖ សង្គមវិជ្ជាទូទៅគឺជាទស្សនៈវិជ្ជានៃ "សង្គមវិជ្ជា" ដែលមានមុខងារបង្កើតនូវទ្រឹស្តីទូទៅសម្រាប់សង្គម។ ទស្សនៈនៃសង្គមវិជ្ជាដែលក្លាយជាទ្រឹស្តីប្រើជាទូទៅសម្រាប់សង្គមវិជ្ជាមានដូចជា ទ្រឹស្តីវិជ្ជមាននិយម ទ្រឹស្តីមុខងារនិយម ទ្រឹស្តីរចនាសម្ព័ន្ធនិយម ។ល។

**៤. ការត្រួតពិនិត្យសង្គម** ៖ ជាផ្នែកនៃសង្គមវិជ្ជាដែលសិក្សាអំពីកត្តាទាំងឡាយរួមមានច្បាប់ ទំនៀមទម្លាប់ ប្រពៃណី និងភាពសមរម្យទាំងឡាយដែលមានឥទ្ធិពលលើការត្រួតពិនិត្យទៅលើបុគ្គលនៅក្នុងសង្គម។

**៥. ដំណើរការសង្គម** ៖ ជាផ្នែកនៃសង្គមវិជ្ជាដែលសិក្សាអំពីដំណើរការនៃការបូកបញ្ចូល និងមិនបូកបញ្ចូលគ្នាដូចជា សហប្រតិបត្តិការ និងទំនាស់។ល។ ដែលមាននៅក្នុងចំណោមមនុស្ស ឬក្រុមនៃមនុស្សជាតិ។

**៦. រោគសាស្ត្រសង្គម** ៖ ជាផ្នែកពិសេសមួយនៃសង្គមវិជ្ជាដែលសិក្សាពិសេសទៅលើកត្តាដែលនាំឱ្យមានការបាត់បង់នូវរបៀបរៀបរយសង្គម និងស្វែងរកនូវមធ្យោបាយមួយសម្រាប់ការពារនូវការបាត់បង់របៀបរៀបរយសង្គម។

ផ្នែកនេះបានក្លាយជាកស្តុតាងសំខាន់បន្ទាប់ពីមានការយកចិត្តទុកដាក់លើផ្នែកនៃសង្គមវិជ្ជាដែលជាទំហំនៃសង្គមមានភាពទូលំទូលាយបំផុត។ ការសិក្សាផ្នែកផ្សេងៗនៃសង្គមវិជ្ជាដូចជា ប្រពៃណីសង្គម ដំណើរការសង្គម សណ្ឋាណសង្គម ។ល។ កត្តានៃលក្ខណៈវិនិច្ឆ័យក្នុងការត្រួតពិនិត្យសង្គមទៅលើរោគសាស្ត្រសង្គម និងទំនាក់ទំនងទៅវិញទៅមក នៃបាតុភូតសង្គមមានឥទ្ធិពលទៅលើជាតុសំខាន់នៃទំនាក់ទំនងសង្គម និងដំណើរការសង្គមស្តីពីជីវភាពសង្គម[25]។

[25] ដកស្រង់ចេញពីសៀវភៅមូលដ្ឋាននៃសង្គមវិជ្ជា( ទំព័រទី៦ដល់ទំព័រទី៨) ក្នុងបណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ




ពន្ធដារកម្ពុជា បានចាប់ផ្តើមមានកំណើតតាំងពីសម័យអាណានិគមនិយមបារាំង គឺមុនកម្ពុជាទទួលបាននូវឯករាជ្យពីអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៥៣។ យោងតាមខ្លឹមសារនៃសៀវភៅស្តីពីហិរញ្ញវត្ថុកម្ពុជា បោះពុម្ពជាភាសាបារាំងដោយសារ ALAIN GOURDON សញ្ជាតិបារាំង និងជាអ្នកជំនាញការអមរាជរដ្ឋាភិបាលសម័យកាលនោះដែលបានរក្សាទុកដោយអតីតអគ្គនាយកដ្ឋានពន្ធដារ (ឯកឧត្តម ស៊ុម អៀង) បានបញ្ជាក់ឱ្យឃើញថារដ្ឋបាលពន្ធដារកម្ពុជា ត្រូវបានបង្កើតឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៥៣ តាមក្រមលេខ៨៣០ NG ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៣ ដែលមានឈ្មោះថានាយកដ្ឋានពន្ធដារកម្ពុជា។ ច្បាប់ដើមនៃសៀវភៅហិរញ្ញវត្ថុនេះមានតម្កល់ទុកនៅសហបណ្ណាល័យរួមនៃទីក្រុងវ៉ាស៊ីនតោន ( Joint library Washington DC 20431 លេខ 106535 ) ។ ឯកសារខាងលើនេះក៏មានរំលេចឱ្យដឹងដែរថាមុនពេលបង្កើតជានាយកដ្ឋានពន្ធដារកម្ពុជានៅក្នុងឆ្នាំ១៩៥៣ ក៏មានការប្រមូលពន្ធផងដែលតាមបែបរចនាសម្ព័ន្ធ ពិសេសម្យ៉ាងកំណត់ដោយអាណាព្យាបាលបារាំងដែលគ្រប់គ្រងដោយនាយកដ្ឋានចំនួន៣ ខុសៗគ្នា ក្រោមការទទួលខុសត្រូវរដ្ឋអំណាច សហ

ព័ន្ធឥណ្ឌូចិន។ ដោយហេតុថា ឯកសារ ឬកំណត់ត្រាប្រវត្តិសាស្ត្រជាច្រើនស្តីពីកម្ពុជាមុនឆ្នាំ១៩៧៥ ត្រូវបានកម្ទេចចោលឬបាត់បង់ក្នុងរបប ប៉ុល ពត ទើបបណ្តាលឱ្យមានការពិបាកក្នុងការរៀបចំចងក្រងដាក់បញ្ចូល។ នៅក្នុងសៀវភៅនេះ ដែលប្រវត្តិពន្ធដារមានគ្រប់ជ្រុងជ្រោយពេញលេញនិងជាក់លាក់។ អ្នកនិពន្ធនឹងខិតខំបន្តស្រាវជ្រាវរកឯកសារ និងព័ត៌មានថែមទៀតស្តីពីពន្ធដារកម្ពុជា ដើម្បីរក្សាទុកជាកំណត់ត្រាប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយ។

បច្ចុប្បន្ននេះ គឺពុំមានព័ត៌មានច្បាស់ការណាមួយស្តីពីសារតា ឬប្រវត្តិពន្ធដារកម្ពុជាក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ នោះទេ ប៉ុន្តែបើយោងតាមការនិយាយតៗគ្នារបស់បុគ្គលមួយចំនួន ដែលធ្លាប់មានការពាក់ព័ន្ធជាមួយពន្ធដារកម្ពុជានៅក្នុង សម័យកាលទសវត្ស១៩៦០ និង១៩៧០ គឺមុនរបបប្រល័យពូជសាសន៍ ប៉ុល ពត សូមបញ្ជាក់ថា ឯកសារ ឬកំណត់ត្រាប្រវត្តិសាស្ត្រមួយចំនួនរបស់កម្ពុជា ត្រូវបានកម្ទេចចោល ឬបាត់បង់ក្នុងរបប ប៉ុល ពត។

បន្ទាប់ពីថ្ងៃរំដោះជាតិមាតុភូមិ ៧មករាឆ្នាំ១៩៧៩ ដែលជាថ្ងៃប្រវត្តិសាស្ត្រដ៏ថ្លៃថ្លានៃការរស់រានមានជីវិតឡើងវិញពីរបបប្រល័យពូជសាសន៍ និងជាសម័យកាលដ៏ខ្មៅងងឹតពោរពេញទៅដោយសោកនាដកម្មដែលស្ថានភាព និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសទាំងមូលត្រូវលិចលង់ធ្លាក់ចុះដុនដាបក្រោមកម្រិតសូន្យទៅទៀតដោយសារការកម្ទេច និងរំលាយចោលដោយរបបកម្ពុជាប្រជាធិតេយ្យរបស់ ប៉ុល ពតហើយដែលប្រជាជនកម្ពុជា និងពិភពលោកទាំងមូលមិនអាចបំភ្លេចបាន។ កម្ពុជានៅពេលនោះ បានចាប់ផ្តើមសារជាថ្មីនូវការខិតខំប្រឹងប្រែងកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឡើងវិញពីចំណុចក្រោមសូន្យលើគ្រប់វិស័យទាំងអស់ដោយរាប់ចាប់ពីវិស័យអប់រំ សុខាភិបាល និងសេដ្ឋកិច្ច។ កត្តាអាទិភាពចម្បងទីមួយៗរបស់រដ្ឋាភិបាលនៃកម្ពុជានៅពេលនោះ គឺការខិតខំបង្កើត និងរក្សាសុខសន្តិភាពជូនប្រទេសជាតិការខិតខំគ្រប់បែបយ៉ាងក្នុងការការពារកុំឱ្យមានការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍ ប៉ុល ពត ក្នុងពេលដែលកម្ពុជាកំពុងខិតខំកសាង និងស្តារប្រទេសជាតិឡើងវិញ។ នាថ្ងៃទី១២ ខែមករា នៅក្នុងឆ្នាំ១៩៧៩ ប្រជាមានិតកម្ពុជា។ រដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាក៏បានបង្កើតឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរដ្ឋការផ្តល់សេវាសាធារណៈ និងការស្តាប់តំបន់ឧស្សាហកម្មសំខាន់ៗសម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច។

នៅដើមឆ្នាំ ១៩៨០ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបានដាក់ឱ្យដំណើរការនូវការប្រមូលចំណូលថវិការរដ្ឋនៅតាមផ្ទះលក់ទំនិញ និងកន្លែងធ្វើអាជីវកម្មធំៗមួយចំនួនតែប៉ុណ្ណោះ ក្រោមរូបភាពជាការធ្វើវិភាគទាន ដែលជាដែនសមត្ថកិច្ចរបស់អង្គភាពមន្ទីរហិរញ្ញវត្ថុដើម្បីជំរុញវិស័យសេដ្ឋកិច្ចឱ្យកាន់តែមានសកម្មភាពផុសផុលបន្ថែមទៀត។

នៅឆ្នាំ១៩៨១ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈប្រជាមានិតកម្ពុជា បានចេញសេចក្តីសម្រេចអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តជាគំរូនូវកិច្ចប្រតិបត្តិការចុះឈ្មោះអាជីវកម្មប្រមូលពន្ធអាជីវកម្ម និងពន្ធលើទំនិញនាំចូលចំពោះមូលដ្ឋានមួយចំនួនតាមរយៈលិខិតលេខ ៧៨ ស.រ.ច ចុះថ្ងៃទី ០៨ខែ កក្កដា ឆ្នាំ១៩៨១។ ផ្អែកតាមខ្លឹមសារនៃសារាចរលេខ ២៤៩-៨១ កហវ.ពដ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨១ ការអនុវត្តជាគំរូនេះគឺ

អនុវត្តតែនៅក្នុងរាជធានីភ្នំពេញ ទីរួមខេត្តកណ្តាល និងស្រុកពញាឬតែប៉ុណ្ណោះ ហើយប្រមូលពន្ធតែទៅលើមូលដ្ឋានអាជីវកម្មផ្នែកពាណិជ្ជកម្មហូបចុក និងបម្រើការងារដែលកិច្ចការនេះស្ថិតក្រោមដែនសមត្ថកិច្ចរបស់នាយកដ្ឋានពន្ធដារឧស្សាហកម្មពាណិជ្ជកម្ម ក្នុងពេលជាបណ្តោះអាសន្នការប្រមូលពន្ធលើមូលដ្ឋានអាជីវកម្មផ្នែកពាណិជ្ជកម្មហូបចុក និងបម្រើការងារគឺអនុវត្តបានតែចំពោះមូលដ្ឋានមួយចំនួន ដែលមានលក្ខណៈហ្នឹងព្រមទាំងមានកម្រិតផលរបរមធ្យមប្រចាំខែតាមតារាង ដែលបានកំណត់ពោល គឺមិនទាន់បានធ្វើការប្រមូលពន្ធអាជីវកម្មដល់មូលដ្ឋានទាំងឡាយណា ដែលលក់ដូរចល័ត ហើយមានផលរបរមធ្យមប្រចាំខែស្ថិតក្រោមកម្រិតដែលតម្រូវឱ្យបង់ពន្ធ និងបណ្តាមូលដ្ឋានអាជីវកម្មចល័តដែលយកផលិតផលកសិកម្ម ឬសត្វចិញ្ចឹមដោយផ្ទាល់មកលក់នៅទីផ្សារ។ ចំពោះផ្នែកផលិតកម្មសិប្បកម្មតូចតាច ផ្នែកសំណង់ដឹកជញ្ជូននេសាទ និងផ្នែកផ្សេងៗទៀតត្រូវបានដាក់ឱ្យបន្តសិក្សាស្រាវជ្រាវដើម្បីរៀបចំដាក់អនុវត្តការប្រមូលពន្ធនៅពេលក្រោយ។

នៅចុងឆ្នាំ១៩៨២ ជាជំហានបន្ទាប់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានដាក់អនុវត្តឱ្យប្រមូលពន្ធកាន់តែទូលំទូលាយក្នុងក្របខណ្ឌទូទាំងប្រទេសលើកលែងតែខេត្តព្រះវិហារ ខេត្តមណ្ឌលគីរី និងខេត្តរតនគីរី តាមរយៈក្រឹត្យច្បាប់លេខ ១៤ ក្រ.ច ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៨២។ បន្ទាប់មកក្រសួងហិរញ្ញវត្ថុបានដាក់អនុវត្តប្រកាសលេខ ២១៤៩-៨២ កហវ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨២ ស្តីពីការណែនាំអនុវត្តក្រឹត្យ-ច្បាប់ពន្ធអាជីវកម្មហូបចុក និងបម្រើការងារដែលកំពុងមានសកម្មភាពក្រោមរូបភាពឯកជន ឬសមូលហភាពដូចជាក្រុមហ៊ុនសមាគម ក្រុមសាមគ្គី សហករណ៍ ក្រុមហ៊ុនចម្រុះរដ្ឋជាដើម។ ចំពោះរបៀបរបបនៃការកំណត់ពន្ធសម្រាប់ការប្រមូលពន្ធនេះ គឺមិនគិតតាមអត្រាទេ ប៉ុន្តែត្រូវគិតតាមផលរបរប្រចាំខែ និងកំណត់ប្រាក់ពន្ធត្រូវបង់តែម្តងមានន័យថា បើផលរបរប្រចាំខែតិចគឺបង់ពន្ធតិច បើផលរបរច្រើនគឺបង់ពន្ធច្រើន។ រហូតដល់ឆ្នាំ១៩៩០ នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជ បានប្តូរឈ្មោះមកជានាយកដ្ឋានពន្ធដារ ហើយនៅតាមបណ្តាខេត្ត-រាជធានីក្រឹត្យលេខ ២៨ អនក្រចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០។ ក្រោយពីការបោះឆ្នោតជាសកលបានដាក់អនុវត្តដោយកំណត់នូវមូលដ្ឋានសម្រាប់ការប្រមូលពន្ធចាប់ពីឆ្នាំ១៩៩៨ រហូតមក។

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ័យ និងបារីដែលជាផលិតផលមកពីបរទេស។
- ពន្ធប៉ាតង់ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីពន្ធប៉ាតង់ និងមាត្រា៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសដោយព្រះរាជក្រមលេខ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូងគឺចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧។
- ពន្ធកាត់ទុកចាប់ផ្តើមគឺចេញពីព្រះរាជក្រមលេខ នស.រកម.០២៩៧ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧។

- ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ១៩៩៧ ចេញដោយព្រះរាជក្រម និងអនុក្រឹត្យលេខ ៨៨ អនុក្រ.បក ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ តែអនុម័តពិតប្រាកដគឺ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩។
- អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤ និង ៦ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា ១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ប្រកាសប្រើដោយព្រះរាជក្រមលេខនស.រកម.១២១៥/០១៦ ចុះថ្ងៃទី ១៧ ធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ១៨២០ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។

នៅក្នុងឆ្នាំ ២០០០ នាយកដ្ឋានពន្ធដារត្រូវបង្កើតឡើងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ២០០៤ ឯកឧត្តម ស៊ុម អៀង ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានពន្ធដារ បន្ទាប់ពី ឯកឧត្តម ហុង ថា។

នៅក្នុងឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដែលមានភារកិច្ចគ្រប់គ្រងរដ្ឋបាលប្រមូលពន្ធដារក្នុងស្រុក (ពន្ធផ្ទៃក្នុង) បង្កើតគោលនយោបាយពន្ធដារក៏ដូចជាធ្វើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ពន្ធ័នឹងការយកពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយមានការកែសម្រួល និងបង្កើតការិយាល័យថ្មីបន្ថែមមួយចំនួនទៀត ដើម្បីសម្រួលដល់ការងារប្រមូលចំណូលពន្ធតាមរយៈអនុក្រឹត្យលេខ ១៣៤ អន.ក្រ.បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៨ ដើម្បីឆ្លើយតប និងសម្របទៅតាមការវិវត្ត និងការបន្តរីកធំឡើង ជាបន្តបន្ទាប់នៃវិសាលភាពប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ ក្រោយពីនាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជា អគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០០៨ ឯកឧត្តមត្រូវបានត្រាស់បង្គាប់តែងតាំងជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដាររហូតមកដល់ឆ្នាំ២០១២។

នៅក្នុងឆ្នាំ២០១២ នេះផងដែរ ឯកឧត្តមក៏ត្រូវបានត្រាស់បង្គាប់តែងតាំងជាអនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាឋានៈស្មើរដ្ឋលេខាធិការ។ ចាប់ពីឆ្នាំ ២០១៣ មកដល់បច្ចុប្បន្នឯកឧត្តម ស៊ុម អៀងជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ២៨។ នៅក្នុងខែសីហា ឆ្នាំ២០១២ ខ្លង់ វិបុល ត្រូវបានតែងតាំងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧៣៨ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១២។ ក្នុងឆ្នាំ ២០១៣ អគ្គនាយកដ្ឋានពន្ធដារត្រូវបានកែសម្រួល និងរៀបចំរចនាសម្ព័ន្ធបន្ថែមទៀតតាមរយៈអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣

ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្តែងឱ្យកាន់តែមានប្រសិទ្ធភាព ដោយបានកំណត់បញ្ជាក់យ៉ាងច្បាស់ថា «អគ្គនាយកដ្ឋានពន្ធដារគឺជារដ្ឋបាលសារពើពន្ធដែលមានប្រព័ន្ធចាត់តាំងឯកភាពទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

ក. ចក្ខុវិស័យ

អគ្គនាយកដ្ឋានពន្ធដារ បានបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានចក្ខុវិស័យជាអង្គភាពសាធារណៈមួយត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្តលើគុណភាព និងជំនាញក្នុងការប្រមូលពន្ធហើយនាពេលអនាគតអគ្គនាយកដ្ឋានពន្ធដារមានចក្ខុវិស័យក្នុងការធ្វើឱ្យមាននូវការទទួលស្គាល់ និងការគោរពពីសំណាក់អ្នកជាប់ពន្ធចំពោះភាពត្រឹមត្រូវ និងគុណភាពនៃការគ្រប់គ្រង។

ខ. បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារមានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងតែង និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធតាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិការផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរពនិង អនុវត្តត្រឹមត្រូវអនុវត្តតាមកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាពមានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ។
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ

គ. គោលដៅ

អគ្គនាយកដ្ឋានពន្ធដារបានកំណត់គោលដៅដូចខាងក្រោមៈ

- រៀបចំទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឪវាទរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការបំពេញការងារពាក់ព័ន្ធនិងពន្ធដារ។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

ក.រចនាសម្ព័ន្ធគ្រប់គ្រង




- ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង
- ឯកឧត្តម **ជាប ជាទុង** អគ្គនាយករង

- ឯកឧត្តម **វ៉ាន់ ពុទ្ធិពល** អគ្គនាយករង
- ឯកឧត្តម **មិញ បានកុសល** អគ្គនាយករង
- ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង
- ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង
- លោកជំទាវ **ម៉ិន នារី** អគ្គនាយិការង។

**ខ. តួនាទី និងភារកិច្ច**

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិការជាតិ
- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាននានាស្តីពីពន្ធដារកំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុកដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិការជាតិប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ១៩៩៩ គឺមាត្រា២៣។ ប៉ុន្តែមាត្រា២៣នេះត្រូវបានប្តូរទៅជាមាត្រា២៣ថ្មីដោយការធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ចំពោះតម្លៃសុរាមេរ័យ និងបារីដែលលក់នៅក្នុងមណ្ឌលដែនដីខេត្ត-ក្រុង។ ដូចនេះមាត្រា២៣នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ត្រូវទុកជានិរាករណ៍។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសេចក្តីជូនដំណឹងមួយលេខ ០០៤ សហវ ចុះថ្ងៃទី០៩ខែមករាឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង និងការប្រមូលអាករបំភ្លឺសាធារណៈ។ ប្រកាសនេះធ្វើឡើងរវាងក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។ ប្រកាសមួយនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើនិយ័តកម្មលើការអនុវត្ត និងការប្រមូលអាករបំភ្លឺសាធារណៈ Tax on public lighting។

ប្រកាស៧ នៃប្រកាសលេខ១៧៥ ខាងលើប្បញ្ញត្តិថា ប្រាក់ចំណូលដែលមកពីការប្រមូលអាករបំភ្លឺសាធារណៈត្រូវបានជាប្រយោជន៍សម្រាប់ថវិការខេត្ត-ក្រុងទុកសម្រាប់ចំណាយឱ្យការបំភ្លឺសាធារណៈ។

**៣.២.២ បុគ្គលជាប់អាករ**

បុគ្គលជាប់អាករសំដៅដល់អ្នកផលិត ឬអ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃកថាខណ្ឌនេះគឺ៖

- អ្នកផលិត សំដៅដល់ម្ចាស់ផលិតផលដែលផលិតផលជាប់អាករដោយខ្លួនឯង ឬដែលជួលបុគ្គលដទៃទៀតឱ្យផលិតនូវផលិតផលជាប់អាករឱ្យខ្លួន។
- អ្នកនាំចូល សំដៅដល់ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬដែលប្រគល់សិទ្ធិឱ្យបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករឱ្យខ្លួន។
- អ្នកផ្គត់ផ្គង់បន្ត សំដៅដល់បុគ្គលដទៃទៀតក្រៅពីអ្នកផលិត ឬអ្នកនាំចូលដែលផ្គត់ផ្គង់បន្តនូវផលិតផលជាប់អាករ។

**៣.២.៣ ផលិតផលជាប់អាករ**

**ក. កម្មវត្ថុ**

យោងតាមប្រកាសលេខ ៩៧៦ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពាក្យ «អាករសម្រាប់បំភ្លឺសាធារណៈ» ត្រូវបានឱ្យនិយមន័យថា ជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ និងបារីបន្ទាប់ពីបាននាំចូល ឬ ផលិតផលជាប់អាករក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈដែលពាក្យ «ផលិតផលជាប់អាករ» សំដៅដល់សុរាមេរ័យ និងបារី។ តាមពិតគ្រឿងស្រវឹងគ្រប់ប្រភេទ និងបារីជាមុខទំនិញពិសេសដែលត្រូវជាប់អាករពិសេស (Special Tax on certain merchandise and service) លើសពីនេះទៅទៀតមុខទំនិញបារី និងគ្រឿងស្រវឹងនេះក៏ជាប់ពន្ធអាករសម្រាប់បំភ្លឺសាធារណៈ (Public lighting Tax)។

**ខ. ផលិតផលជាប់អាករ**

ផលិតផលជាប់អាករ សំដៅដល់សុរាមេរ័យ និងបារី។

- សុរា សំដៅដល់ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល។
- មេរ័យ សំដៅដល់ទឹកស្រវឹងដែលធ្វើឡើងដោយត្រាំគ្រឿងផ្សំផ្សេងៗដែលមានដូចខាងក្រោម៖
  - ស្រាបៀ
  - ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា
  - ស្រាវ៉ែមុត និងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតពីរុក្ខជាតិ និងសារជាតិក្រអូប
  - ភេសជ្ជៈមេរ័យផ្សេងទៀត លើកលែងតែទឹកត្នោតជូរ និងស្រាស
  - អាល់កុលអេទីលិកសុទ្ធដែលមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី៨០% នៃចំណុច ឬលើសពីនេះ និងអាល់កុលអេទីលិក និងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កម្រិតសុរាដើមរបស់វា
  - អាល់កុលអេទីលិកបាត់បង់ជាតុសុទ្ធដែលមានកម្រិតជាតិសុរាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗ ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់

ផលិតភេសជ្ជៈ។

- ថ្នាំជក់ សំដៅដល់ផលិតផលទាំងមូល ឬមួយផ្នែកដែលធ្វើដោយស្លឹកថ្នាំជក់ដែលជាវត្ថុធាតុដើមហើយ ដែរផលិតសម្រាប់យកទៅជក់។
- ពាក្យ "បារី" សំដៅដល់ផលិតផលសម្រាប់ជក់គ្រប់ប្រភេទដែលផលិតឡើងពីថ្នាំជក់។ ពាក្យ "បារី" ក៏ រួមបញ្ចូលផងដែរនូវបារីអេឡិចត្រូនិកគ្រប់ប្រភេទ។









ផ្អែកតាមប្រកាសខាងលើដដែលអ្នកដែលមានការតព្វកិច្ចត្រូវបង់អាករសម្រាប់បំភ្លឺសាធារណៈ គឺជាអ្នក ផលិត អ្នកនាំចូល និងអ្នកផ្គត់ផ្គង់បន្ត នូវផលិតផលជាប់អាករ និងត្រូវបង់នៅពេលផ្គត់ផ្គង់ឬផ្គត់ផ្គង់បន្ត។ ក្នុង នោះផងដែរអាករសម្រាប់បំភ្លឺសាធារណៈក៏ត្រូវបានលើកលែងទៅលើះ

- ស្រាដែលផលិតលក្ខណៈគ្រួសារ
- ទឹកត្នោតជូរ
- ថ្នាំជក់ វត្ថុធាតុដើម។









### ៣.២.៤ ការគណនាអាករបំភ្លឺសាធារណៈ

ដើម្បីគណនាអាករត្រូវបង់បុគ្គលជាប់អាករត្រូវធ្វើការបែងចែកឱ្យបានផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ័យ, បារីជាប់អាករ និងផលរបរដែលបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀត។ មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម៖

១. ចំពោះអ្នកផលិត និងអ្នកនាំចូល មូលដ្ឋានគិតអាករគឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ក្នុងវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់សាធារណៈខ្លួនឯង។

សម្រាប់វិក្កយបត្រអាករ-អ្នកផលិត និងអ្នកនាំចូល

មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ+អាករពិសេស

សម្រាប់វិក្កយបត្រធម្មតា

មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្ររួមអាករ ៖ អតប ៖អាករបំភ្លឺសាធារណៈខ្លួនឯង

អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករ x អត្រាអាករ



- **ការគណនាអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់អ្នកផលិត**

- ពាក្យ «អ្នកនាំចូល» សំដៅដល់បុគ្គលណាដែលធ្វើការនាំចូលដោយខ្លួនឯង ឬដោយបុគ្គលដទៃទៀតមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

- **ការគណនាអាករបំភ្លឺសាធារណៈសម្រាប់អ្នកនាំចូល**

| ល.រ N$^0$ | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករ បំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|
| | A | B | D=B*3% | E=(B+C)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 50,000 | 105,000 | 1,155,000 |
| 2 | ស្រាបៀ | 1,500,000 | 75,000 | 157,500 | 1,732,500 |
| 3 | បារី | 500,000 | 25,000 | 52,500 | 577,500 |
| សរុបរួម | | 3,000,000 | 150,000 | 315,000 | 3,465,000 |

២. ចំពោះអ្នកផ្គត់ផ្គង់បន្តមូលដ្ឋានគិតអាករស្មើនិង ២០% នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករលើតម្លៃបន្ថែម (អ.ស.ប) និងអាករបំភ្លឺសាធារណៈខ្លួនឯង (អ.ប.ស)។

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត (សេវាកម្សាន្ត)
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = (តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ+អាករពិសេស) × ២០%

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ × ២០%

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = (តម្លៃសរុបលើវិក្កយបត្ររួមអាករ ៖ អតប ៖ អាករបំភ្លឺសាធារណៈខ្លួនឯង) × ២០%

អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករ × អាត្រាអាករ



- ពាក្យ «អ្នកផ្គត់ផ្គង់» សំដៅដល់បុគ្គលដទៃទៀតក្រៅពីអ្នកផលិត ឬអ្នកនាំចូលដែលផ្គត់ផ្គង់បន្តនូវផលិតផលជាប់អាករ។

- ការគណនាអាករបំភ្លឺសាធារណៈសម្រាប់អ្នកផ្គត់ផ្គង់បន្ត

| ល.រ N0 | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករ បំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|
| | A | B | D=(B*20%)*3% | E=(B+C)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 10,000 | 101,000 | 1,111,000 |
| 2 | ស្រាបៀ | 1,500,000 | 15,000 | 151,500 | 1,666,500 |
| 3 | បារី | 500,000 | 5,000 | 50,500 | 555,500 |
| សរុបរួម | | 3,000,000 | 30,000 | 303,000 | 3,333,000 |

- អត្រាអាករសម្រាប់បំភ្លឺសាធារណៈគឺ ៣%។
- កាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់លិខិតប្រកាស និងបង់ប្រាក់អាករយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

**៣.២.៥ នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈ**

ការប្រមូលប្រាក់អាករនាពេលបច្ចុប្បន្នក៏ដូចជាការប្រមូលប្រាក់ពន្ធដទៃទៀតដែរ គឺអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការគណនាពន្ធដោយខ្លួនឯង បំពេញលិខិតប្រកាសបង់ពន្ធ ហើយធ្វើការបង់នៅតាមធនាគារដើម្បីផ្តល់សុវត្ថិភាពដល់ថវិការរដ្ឋ។

- **ជម្រើសទី១**

ដើម្បីភាពងាយស្រួល និងឆាប់រហ័សទាន់ចិត្តអ្នកជាប់ពន្ធអាចចូលទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារហើយធ្វើការបន្តនៅតាមធនាគារនាយកដ្ឋានពន្ធដារ (WWW.tax.gov.kh) ដោយស្វែងរកពាក្យ«ការប្រកាសបង់ប្រាក់ពន្ធ» ហើយអនុវត្តន៍តាមលំដាប់លំដោយ និងការណែនាំនៅក្នុងគេហទំព័រដូចខាងក្រោម៖

- បំពេញការិយបរិច្ឆេទនៃការបង់ពន្ធរបស់ខ្លួន(ខែ ឆ្នាំ ពីថ្ងៃ ដល់ថ្ងៃ)
- ជ្រើសរើសប្រភេទពន្ធ និងបំពេញចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុង លិខិតប្រកាស
- ជ្រើសរើសកម្រៃសេវាផ្សេងៗ និងបំពេញទឹកប្រាក់ដែលត្រូវបង់(ប្រសិនបើមាន)។
- ត្រូវបំពេញចំនួនទំព័រនៃទម្រង់លិខិតប្រកាសនីមួយៗ
- នៅពេលបំពេញរួចត្រូវបោះពុម្ព (Print) លិខិតស្នើសុំបង់ប្រាក់ពន្ធចេញពីប្រព័ន្ធគ្រប់គ្រងដែលមាន Barcode សម្រាប់សម្គាល់ចេញពីម៉ាស៊ីនបោះពុម្ព (Printer) ហើយអ្នកជាប់ពន្ធអាចយកលិខិតនេះទៅបង់ពន្ធ នៅធនាគារណាមួយដែលទទួលបន្ទុកទទួលប្រាក់បង់ពន្ធ។

❖ ជម្រើសទី២

ក្នុងករណីអ្នកជាប់ពន្ធមិនសូវចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធ Online អ្នកជាប់ពន្ធត្រូវទៅធនាគារណាមួយដែលទទួលបន្ទុកប្រាក់បង់ពន្ធ ហើយអនុវត្តន៍តាមជំហាននីមួយៗដូចខាងក្រោម៖

- បំពេញទម្រង់បង់ប្រាក់ពន្ធ (Form101) នូវប្រភេទពន្ធ និងចំនួនទឹកប្រាក់ពន្ធដែរត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស។
- ដាក់ទម្រង់បង់ប្រាក់ពន្ធ (Form101) ដែលបំពេញរួចជូនរដ្ឋមន្ត្រីធនាគារដើម្បីបង់ប្រាក់ពន្ធ។ ធនាគារចំនួនបីដែលទទួលខុសត្រូវក្នុងការប្រមូលពន្ធជូនរដ្ឋមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ក.អ និងធនាគារវឌ្ឍនៈ។

ក្រោយពេលទទួលប្រាក់ពន្ធគ្រប់ចំនួនរួចហើយ ភាគីធនាគារត្រូវបោះពុម្ព(Print) បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ( tax Payment Receipt) ចេញពីប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារដែលមាន៣សន្លឹកគឺ៖ សន្លឹកទី១ ពណ៌ស សម្រាប់មន្ត្រីពន្ធដាររក្សាទុក សន្លឹកទី២ ពណ៌ផ្កាឈូកសម្រាប់ប្រគល់ឱ្យអ្នកជាប់ពន្ធ និងសន្លឹកទី៣ ពណ៌លឿង សម្រាប់ធនាគារ។

លើសពីនេះទៅទៀតតាមរយៈកំណែទម្រង់ថ្មីខាង អគ្គនាយកដ្ឋានពន្ធដារបានផ្តល់នូវសេចក្តីទុកចិត្តដល់សហគ្រាសដែលជាអ្នកជាប់ពន្ធដោយការជូនដំណឹងដោយស្វ័យប្រវត្តិ (Automate and generate SMS & email ) តាមរយៈការផ្ញើសារ ឬតាម E-mail បញ្ជាក់ថាសហគ្រាសនោះបានបង់ប្រាក់ពន្ធ និងកាលបរិច្ឆេទដែលបានចែងក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធ បើសិនជាអ្នកជាប់ពន្ធដែលជាម្ចាស់សហគ្រាសបានផ្តល់លេខទូរស័ព្ទ និង E-mail មកអគ្គនាយកដ្ឋានឱ្យបានត្រឹមត្រូវ។ ចំណែកឯប្រភេទពន្ធនីមួយៗនិងទឹកប្រាក់សរុប គឺមានលម្អិតនៅក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធដែលចេញជាផ្លូវការ។

**លំហូរនៃទឹកប្រាក់ពន្ធចូលថវិកាជាតិ**




រូបភាពខាងលើមានអត្ថន័យដូចខាងក្រោម៖

គំនូសបំព្រួយទី១៖ អ្នកជាប់ពន្ធធ្វើការបង់ប្រាក់នៅធនាគារទទួលបន្ទុកប្រមូលប្រាក់ពន្ធនីមួយៗ។

គំនូសបំព្រួយទី២៖ ក្រោយពីទទួលបានការបង់ប្រាក់ពន្ធ-អាករធនាគារធ្វើការផ្ទេរនូវប្រាក់ទាំងអស់ចូលទៅក្នុងរតនាគារជាតិកម្ពុជា ដើម្បីទុកជាថវិការរដ្ឋសម្រាប់ការចំណាយផ្សេងៗ។ ខាងក្រោមនេះគឺជាទិន្នន័យនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេលពីរបីឆ្នាំជាប់គ្នាគិតចាប់ពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៣។

| ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|
| ២០២២ | ២០២៣ | ចំនួនទឹកប្រាក់ | ភាគរយ |
| ១៦១,៨៥៩២.០លានរៀល | ២៣៧,៨២០.៨០លានរៀល | ៧៥,៩១១.៦០លានរៀល | ៤៦.៩០% |

**៣.២.៦ ការទទួលលិខិតប្រកាស**

ក្រោយពេលបានបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធ ហើយអ្នកជាប់ពន្ធត្រូវភ្ជាប់បង្កាន់ដៃនេះ (សន្លឹកទី១៖ ពណ៌ស សម្រាប់មន្ត្រីពន្ធដារ) ជាមួយលិខិតប្រកាសពន្ធដែលមានចុះហត្ថលេខា និងត្រាត្រឹមត្រូវ ហើយភ្ជាប់មកជាមួយនឹងឯកសារដែលពាក់ព័ន្ធនានាមកដាក់ជូនមន្ត្រី ទទួលលិខិតប្រកាសនៅអង្គភាពពន្ធដារទទួលបន្ទុកបន្ទាប់មកមន្ត្រីទទួលលិខិតប្រកាស និងបោះពុម្ពជូនលិខិតបញ្ជាក់ការទទួលលិខិតប្រកាសភ្លាមៗ។

ចំពោះបង្កាន់ដៃទទួលប្រាក់ពន្ធទាំងឡាយណា ដែលខុសពីបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធដូចមាននៅក្នុងសេចក្តីណែនាំនេះ អគ្គនាយកដ្ឋានពន្ធដារពុំទទួលស្គាល់ថា សហគ្រាសបានបង់ពន្ធតាមប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារនោះទេ។

ក្រោយពីទទួលបានលិខិតប្រកាសពន្ធចំនួនបីច្បាប់ពីអ្នកជាប់ពន្ធ មន្ត្រីទទួលលិខិតប្រកាសពន្ធធ្វើការពិនិត្យ ថាតើអ្នកជាប់ពន្ធបានបង់ត្រឹមត្រូវ តាមការបំពេញនៅក្នុងលិខិតប្រកាសពន្ធ និងមានឯកសារយោងច្បាស់លាស់ភ្ជាប់មកជាមួយដែរឬទេ។ ឧទាហរណ៍ សម្រាប់អាករបំភ្លឺសាធារណៈមន្ត្រីពន្ធធ្វើការពិនិត្យលើចំណុច មួយចំនួនដូចខាងក្រោម៖

- ចំនួនទឹកប្រាក់ដែលអ្នកជាប់ពន្ធបង់ទៅធនាគារត្រូវស្មើនិងចំនួននៅក្នុងលិខិតប្រកាស
- ទិន្នានុប្បវត្តិទិញ លក់ត្រូវតែដូចនូវអ្វីដែរបំពេញក្នុងលិខិតប្រកាស
- វិក្ក័យបត្រអាករក្នុងករណីអ្នកជាប់ពន្ធស្នើសុំឥណទានអាករលើធាតុចូល
- ហត្ថលេខានិងត្រា ត្រូវតែមាននៅគ្រប់លិខិតប្រកាស អតប និងទិន្នានុប្បវត្តិទិញលក់...។

ក្រោយពីធ្វើការពិនិត្យរួចរាល់ ហើយបើសិន ជាត្រឹមត្រូវដូចចំណុចរៀបរាប់ខាងលើមន្ត្រីទទួលលិខិតប្រកាសធ្វើការចេញនូវលិខិតបញ្ជាក់ ការទទួលលិខិតប្រកាស ហើយប្រគល់ឯកសារចំនួន១ច្បាប់ទៅឱ្យអ្នកជាប់ពន្ធរក្សាទុក ក៏ដូចជាផ្ញើរសារដោយស្វ័យប្រវត្តិទៅកាន់ម្ចាស់សហគ្រាសថា បានទទួលលិខិតប្រកាសរួចរាល់ហើយ។ ក្នុងករណីដែលមន្ត្រីពន្ធធ្វើការពិនិត្យឃើញថា អ្នកជាប់ពន្ធធ្វើការប្រកាសពន្ធមិនមានភ្ជាប់ឯកសារត្រឹមត្រូវឬទឹកប្រាក់បង់ពន្ធខុសពីឯកសារភ្ជាប់មន្ត្រីពន្ធធ្វើការជូនដំណឹងទៅអ្នកជាប់ពន្ធភ្លាមៗឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវវិញ។ ការចេញលិខិតបញ្ជាក់ ការទទួលលិខិតប្រកាសពន្ធមិនបញ្ជាក់ថាអ្នកជាប់ពន្ធត្រឹមត្រូវនោះទេលុះត្រាតែមន្ត្រីទទួលបន្ទុកធ្វើការពិនិត្យម្តងទៀតតាមរយៈការវាយបញ្ចូលនូវពន្ធ-អាករដែលអ្នកជាប់ពន្ធបានប្រកាសនៅក្នុងប្រព័ន្ធកត់ត្រាពន្ធផ្ទៃក្នុងរបស់ពន្ធដារ (Tax Collection System) ដែលចងក្រងជារូបមន្តនិងគណនាចំនួនទឹកប្រាក់ពន្ធដោយស្វ័យប្រវត្តិ នោះនឹងដឹងថាសហគ្រាសណាដែលគណនា និងបង់ពន្ធត្រឹមត្រូវទៅតាមការប្រកាស។

ក្នុងករណីដែលពិនិត្យ និងផ្ទៀងផ្ទាត់ឃើញថា អ្នកជាប់ពន្ធធ្វើការគណនា និងបង់ពន្ធត្រឹមត្រូវតាមការប្រកាស ហើយខាងការិយាល័យចាត់ចែងទទួលលិខិតប្រកាសធ្វើការរក្សាទុកឯកសារមួយច្បាប់សម្រាប់បញ្ជូនទៅអគ្គនាយកដ្ឋានពន្ធដារ និងមួយច្បាប់ទៀតទុកតម្កល់នៅសាខាពន្ធដារខណ្ឌដោយធ្វើការរក្សាទុករយៈពេល១០ឆ្នាំ។ ក្នុងរយៈពេលចុងក្រោយនេះរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមរឹតបន្តឹងច្បាប់បង់ពន្ធបន្តិចម្តងៗ។ ជាក់

ស្តែងឥឡូវនេះ រដ្ឋាភិបាលបានជំរុញបន្ថែមទៀតឲ្យប្រជាពលរដ្ឋបង់ពន្ធលើប្រាក់ខែ។ អ្នកដែលទទួលបានប្រាក់ខែ ក្នុងចន្លោះពី៣០០ដុល្លារដល់ជាង៣ពាន់ដុល្លារអាមេរិក ត្រូវជាប់កាតព្វកិច្ចបង់ពន្ធក្នុងចន្លោះពី៥%ទៅ២០% តែអ្នកដែលទទួលបានប្រាក់បៀវត្សក្រោមពី៣០០ដុល្លារអាមេរិក មិនតម្រូវឲ្យបង់ពន្ធឡើយ។

ក្រៅពីការបង់ពន្ធលើប្រាក់ខែ ប្រជាពលរដ្ឋត្រូវបង់ពន្ធលើអចលនទ្រព្យ ពន្ធលើយានជំនិះ ពន្ធលើប្រាក់ចំណេញ និងពន្ធដារផ្សេងៗទៀត។ ការបង់ពន្ធ គឺជារឿងធម្មតាសម្រាប់ប្រទេសជឿនលឿន ប៉ុន្តែសម្រាប់ប្រទេសក្រីក្រកម្ពុជាវិញ ការបង់ពន្ធហាក់បីដូចជារឿងថ្មីហើយពួកគេមិនចង់ចូលរួមបង់ពន្ធទេ។ តើនេះបណ្តាលមកពីមូលហេតុអ្វី ?

កាលពីពេលមុនរដ្ឋាភិបាលនៃប្រទេសកម្ពុជា ពឹងផ្អែកខ្លាំងទៅលើប្រាក់ចំណូលបានពីពន្ធគយសម្រាប់ការអភិវឌ្ឍន៍ជាតិ ប៉ុន្តែដោយសារពន្ធគយត្រូវបានប្រទេសក្នុងតំបន់អាស៊ានព្រមព្រៀងគ្នាកាត់បន្ថយបន្តិចម្តងៗក្នុងចំណោមសមាជិករបស់ខ្លួននោះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាចាប់ផ្តើមសម្លឹងមើលប្រភពចំណូលផ្សេងក្រៅពីប្រាក់ចំណូលពន្ធគយ។ ប្រាក់ចំណូលដែលរដ្ឋាភិបាលកម្ពុជាបាននិងកំពុងសម្លឹងមើលសម្រាប់បំពេញថវិកាជាតិនាពេលខាងមុខនេះគឺប្រាក់ចំណូលពន្ធដារ។ ចំណូលពន្ធដារគឺជាប្រាក់ចំណូលដែលរដ្ឋាភិបាល ប្រមូលក្នុងប្រទេស ដូចជាៈពន្ធលើប្រាក់ខែ ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធលើប្រាក់ចំណេញ និងពន្ធលើសេវាកម្មមួយចំនួនផ្សេងទៀត។ អ្វីដែលជាការកត់សម្គាល់ គឺថានៅគ្រាចុងក្រោយនេះរដ្ឋាភិបាលបានជំរុញការប្រមូលពន្ធលើអចលនទ្រព្យ ដីធ្លី ផ្ទះសម្បែង ពន្ធលើយានជំនិះ និងពន្ធលើប្រាក់ខែ។ ប្រភេទពន្ធទាំងនេះមិនថ្មីទេសម្រាប់ប្រទេសជឿនលឿនគោរពច្បាប់ប៉ុន្តែ សម្រាប់ប្រទេសក្រីក្រកម្ពុជាទើបងើបចេញពីសង្គ្រាមប្រភេទពន្ធនេះហាក់បីដូចជាអំរែកថ្មីមួយទៀតសម្រាប់ប្រជាជន។ ហើយពន្ធលើប្រាក់បៀវត្សក៏ជាការដាក់សម្ពាធបន្ថែមទៀតសម្រាប់បុគ្គលិក កម្មករ និងមន្ត្រីរាជការ។

នៅក្នុងប្រទេសគោរពច្បាប់ការបង់ពន្ធគឺជាកាតព្វកិច្ចមិនអាចគេចវេសបានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាវិញកាតព្វកិច្ចបង់ពន្ធមិនថាពន្ធគយឬពន្ធដារទេនៅមានភាពធូររលុង។ ឈ្មួញមួយចំនួនព្យាយាមមិនបង់ពន្ធក្នុងខណៈពេលដែលឈ្មួញមួយចំនួនផ្សេងទៀតសុខចិត្តបង់ពន្ធតាមការទាមទាររបស់រដ្ឋ។ ចំពោះពន្ធលើប្រាក់ខែ និងពន្ធលើអចលនទ្រព្យ ដីធ្លី ផ្ទះសម្បែងគេសង្កេតឃើញថាប្រជាជនមួយចំនួនចាប់ផ្តើមយល់ដឹងពីកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ ពួកគេខ្នះខ្នែងបំពេញក្រដាសស្នាមខ្លួនឯងហើយយកប្រាក់ទៅបង់ជូនរដ្ឋ។ ប៉ុន្តែប្រជាពលរដ្ឋខ្លះទៀតនៅធ្វើព្រងើយកន្តើយនឹងរឿងនេះនៅឡើយ។ ភាពព្រងើយកន្តើយរបស់ប្រជាពលរដ្ឋនេះហើយដែលមិនមែនកើតឡើងដោយសារពួកគេនោះទេ។ តាមពិត គឺដោយសារតែប្រជាជនមួយចំនួននៅចោទជាសំណួរថា តើប្រាក់ដែលបង់ពន្ធជូនរដ្ឋនេះវាទៅទីណា ? ហើយគេយកទៅធ្វើអ្វីឱ្យប្រាកដ ? តើការប្រមែប្រមូលពន្ធមានតម្លាភាពដែរឬទេ ?ជាធម្មតាការប្រមូលពន្ធមិនថានៅប្រទេសជឿនលឿនគោរពច្បាប់ឬនៅកម្ពុជាទេ គោលការណ៍គឺសម្រាប់បម្រើផលប្រយោជន៍របស់រដ្ឋ មានន័យថាជាមួយនឹងទឹកប្រាក់ពន្ធនេះរដ្ឋាភិបាលត្រូវយកទៅចំណាយសម្រាប់កសាងផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យនិងសម្រាប់កសាង

ហេដ្ឋារចនាសម្ព័ន្ធដទៃទៀត។ ម្យ៉ាងវិញទៀតទឹកប្រាក់មួយចំណែកត្រូវរក្សាទុកសម្រាប់ប្រាក់ចូលនិវត្តន៍នៃប្រជាពលរដ្ឋរបស់ខ្លួន។

សម្រាប់ប្រទេសកម្ពុជា ដោយសារតែការបង់ពន្ធជាវប្បធម៌ថ្មី និងដោយសារតែការមិនទុកចិត្តលើសេវារបស់រដ្ឋនោះប្រជាពលរដ្ឋនៅអល់អែក និងចោទជាសំណួរមិនចេះចប់មិនចេះហើយជុំវិញបញ្ហាបង់ពន្ធនេះ។ អ្នកខ្លះបន្តសំណួរថា ប្រសិនបើគេបង់ពន្ធជូនរដ្ឋគ្រប់ប្រភេទពន្ធទាំងអស់ តើពួកគេអាចទទួលបានអ្វីពីរដ្ឋវិញនៅពេលដែលពួកគេចូលនិវត្តន៍នោះ ? ពន្ធចេះតែបង់តែពេលចាស់ទៅរដ្ឋាភិបាលគ្មានបានគិតគូរអ្វីទាំងអស់។ សម្រាប់មន្ត្រីរាជការរដ្ឋពួកគេអាចទទួលបានប្រាក់ចូលនិវត្តន៍ខ្លះតែចំពោះបុគ្គលិកអង្គការក្រុមហ៊ុនឯកជនវិញតើពួកគេរំពឹងបានអ្វីពីរដ្ឋាភិបាល ?

សរុបសេចក្តីមកវិញ ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្តហើយចូលរួមបង់ពន្ធដើម្បីកសាងប្រទេសជាតិយន្តការនៃការប្រមូលពន្ធត្រូវធ្វើឡើងដោយតម្លាភាពពន្ធត្រូវបម្រើផលប្រយោជន៍ជាតិ និងរបស់ប្រជាជន។ ប្រាក់ចំណូលបានមកពីពន្ធដារ ឬពន្ធគយត្រូវតែចូលទៅក្នុងបេឡារបស់រដ្ឋពោលគឺមិនមែនចូលក្នុងហោប៉ៅរបស់បុគ្គលណាមួយនោះទេ។

លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបាននិយាយថាកំណើនសេដ្ឋកិច្ច និងការវិនិយោគបានធ្វើឱ្យការប្រមូលចំណូលពន្ធអាកររបស់អគ្គនាយកដ្ឋានពន្ធដារបន្តកើនឡើងជារៀងរាល់ឆ្នាំ។

## ៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារបានផ្តល់ផលប្រយោជន៍ដល់សង្គមជាតិដូចខាងក្រោម៖

- អាករបំភ្លឺសាធារណៈជាប្រភេទចំណូលដ៏សំខាន់សម្រាប់ទ្រទ្រង់ ថវិការក្រោមជាតិដើម្បីបំភ្លឺភ្លើងសាធារណៈនៅតាម ភូមិ ឃុំ ស្រុក ខេត្ត-ក្រុង
- ចូលរួមចំណែកក្នុងថវិការជាតិដើម្បីឱ្យរដ្ឋមានថវិកាយកទៅប្រើប្រាស់លើចំណាយផ្សេងៗដោយមិនចាំបាច់បោះពុម្ពលុយដែលអាចបង្កឱ្យមានបញ្ហាជាអតិបរមា។
- ជួយបង្កើនចំណូលមួយផ្នែកនៃការអភិវឌ្ឍន៍ប្រទេសជាតិ។
- អាករបំភ្លឺសាធារណៈក៏បានរួមចំណែកក្នុងការលើកស្ទួយសោភ័ណ្ឌភាព ជាពិសេសនៅតាមទីប្រជុំជននានាឱ្យកាន់តែទាក់ទាញ។
- បង្កជាភាពងាយស្រួលក្នុងការធ្វើចចរាចរណ៍នាពេលរាត្រី
- ការបំភ្លឺភ្លើងសាធារណៈនៅតាម ភូមិ ឃុំ ស្រុក ខេត្ត-ក្រុងបានផ្តល់សុខសុវត្ថិភាពដល់ប្រជាពលរដ្ឋ។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

តាមការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តន៍ជាក់ស្តែង គឺការវិភាគដែលមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីឱ្យដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ហើយនឹងចេះកែប្រែចំណុចខ្សោយឱ្យទៅជាចំណុចខ្លាំងពេលនោះហើយប្រទេសជាតិនឹងមានការរីកចម្រើនទៅមុខជានិច្ច។

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការស្រាវជ្រាវកន្លងមកទៅលើការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារក្រុមនាងខ្ញុំបានវិភាគឃើញទៅលើចំណុចខ្លាំងមួយចំនួនមានដូចជា៖

- ការប្រមូលអាកររបស់អគ្គនាយកដ្ឋានពន្ធដារបានបង្កើននូវប្រសិទ្ធភាពនៃប្រព័ន្ធធនាគារជាតិ និងពង្រឹងវិស័យសារពើពន្ធ។
- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារបានផ្តល់ប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈ។
- អគ្គនាយកដ្ឋានពន្ធដារមាននូវការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- អគ្គនាយកដ្ឋានពន្ធដារមានច្បាប់ស្តីពីការគ្រប់គ្រង និងប្រមូលអាករបំភ្លឺសាធារណៈច្បាស់លាស់ដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។
- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជាការពង្រឹងការអនុវត្តវិធានការប្រមូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ការរីកចម្រើននៃជីវភាពរបស់ប្រជាជនដែលធ្វើឱ្យការប្រើប្រាស់មានការកើនឡើង។
- អគ្គនាយកដ្ឋានពន្ធដារដែលតែងតែបង្កើតនូវសិក្ខាសាលាណែនាំ ដល់អ្នកជាប់ពន្ធទាំងអស់ឱ្យយល់ដឹងពីការកាតព្វកិច្ចនិងសិទ្ធិរបស់ពួកគេចំពោះរដ្ឋ ក៏ដូចជាចំណេះដឹងទាក់ទងនឹងពន្ធដារដើម្បីធ្វើការបង់ប្រាក់និងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។
- អគ្គនាយកដ្ឋានពន្ធដារដែលតែងតែអនុវត្តន៍នូវយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងការផ្តល់ជាការបង្រៀនបន្ថែមដល់មន្ត្រីពន្ធដូចជាការផ្តល់សេវាកម្មពន្ធដារ និងការផ្តល់នូវភាពងាយស្រួលដល់អ្នកជាប់ពន្ធដែលតាមរយៈការធ្វើកំណែទម្រង់ពាក់ព័ន្ធ និងការធ្វើទំនើបកម្មបច្ចេកទេសវិទ្យាដែលរួមមានការបង្ហោះច្បាប់អនុក្រឹត្យប្រកាស និងព័ត៌មានផ្សេងៗទាក់ទងនឹងពន្ធដារនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារការចុះបញ្ជី និងប្រកាសបង់ប្រាក់ពន្ធតាម Online ជាដើម។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនិងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈកាន់តែប្រសើរឡើងដូចជា៖

- នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារមិនមានភាពទូលំទូលាយ ដែលធ្វើឱ្យអ្នកជាប់ពន្ធមួយចំនួនមិនសប្បាយចិត្ត និងមិនសហការក្នុងភារកិច្ចនេះ។
- អគ្គនាយកដ្ឋានពន្ធដារមិនមាននូវផែនការ ឬគោលការណ៍សំខាន់ៗដើម្បីពន្យល់ ឬអប់រំទៅដល់អ្នកជាប់ពន្ធតាមមូលដ្ឋាននីមួយៗជាក់ស្តែង។
- អគ្គនាយកដ្ឋានពន្ធដារមិនបានផ្តល់នូវព័ត៌មានច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់អ្នកជាប់ពន្ធក្នុងការបង់ប្រាក់ពន្ធជូនពន្ធដារនៅឡើយ ដោយពួកគេគិតថាទឹកប្រាក់ដែលពួកគេបានបង់ជូនរដ្ឋមិនបានផ្តល់ប្រយោជន៍អ្វីទេដល់ពួកគេ។
- ដំណើរការនៃការបង់ប្រាក់ពន្ធនៅមានភាពយឺតយ៉ាវនៅឡើយដោយសារតែប្រតិបត្តិការនៃការបង់ប្រាក់ពន្ធនៅមានភាពមិនច្បាស់លាស់ពីបែបបទ និងវិធីសាស្រ្តនៃការគណនានៅឡើយ។
- ការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ និងសេវានានារបស់អគ្គនាយកដ្ឋានពន្ធដារទៅកាន់សាធារណៈជនមិនមានភាពទូលំទូលាយ។
- ចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានប្រមូលមកពីអាករបំភ្លឺសាធារណៈ គឺទុកសម្រាប់ចំណាយទៅលើការបំភ្លឺភ្លើងសាធារណៈនៅតាមខេត្ត-ក្រុង ប៉ុន្តែនៅតាមទីជនបទដាច់ស្រយោលមិនមានការបំភ្លឺភ្លើងសាធារណៈទេ។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវកន្លងមកនេះ ក្រុមរបស់នាងខ្ញុំបាន សង្កេតឃើញថាការប្រមូលពន្ធអាកររបស់អគ្គនាយកដ្ឋានពន្ធដារមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ភាពរីកចម្រើនលូតលាស់ទាំងអស់នេះហើយដែលជាផ្នែកមួយជួយដល់ប្រទេសជាតិដែលបានមកពីការបង់ពន្ធរបស់ប្រជាពលរដ្ឋ លើសពីនេះយើងក៏ឃើញដែរថាមានការកើនឡើងច្រើននៃចំនួនអ្នកជាប់ពន្ធជាបន្តបន្ទាប់ ដែលអាចជួយទ្រទ្រង់ដល់ការផ្គត់ផ្គង់ចំណាយផ្សេងៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ រួមទាំងការបំភ្លឺសាធារណៈទូទាំងប្រទេសកម្ពុជាដែលជួយឱ្យមានតម្លាភាព និងប្រសិទ្ធិភាពនៃការរីកចម្រើនជីវភាពរបស់ប្រជាជន។ ទន្ទឹមនឹងភាពវិជ្ជមានដែលបានលើកឡើងខាងលើនេះ តាមការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញថាកង្វះខាតមួយចំនួន តម្រូវអោយមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលកាន់តែប្រសើរឡើងគឺអ្នកជាប់ពន្ធនៅតែមិនទាន់យល់ច្បាស់ពី ការបង់ពន្ធដែលធ្វើឱ្យពួកគេគិតថាមិនទទួលបាននូវប្រយោជន៍អ្វីសោះដល់ពួកគេ មួយវិញទៀតច្បាប់នៃការបង់ពន្ធមានភាពធូរលុង ដំណើរការបង់ពន្ធនូវតែមានភាពយឺតយ៉ាវដោយសារតែប្រតិបត្តិការមួយចំនួនមិនច្បាស់លាស់ បែបបទនិតិវិធីមួយចំនួននៃបង់សាច់ប្រាក់ដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវចំណាយពេលវេលាច្រើនក្នុងដំណើរការដាក់លិខិតប្រការឱ្យបានត្រឹមត្រូវ។

សរុបជារួម ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈបានផ្តល់ប្រយោជន៍ជាច្រើនដល់សង្គមជាតិ បើទោះបីជា ប្រជាជនមិនទាន់យល់ដឹងច្បាស់ពីការបង់ពន្ធក៏ដោយក៏ពួកគេនៅតែបំពេញកាតព្វកិច្ចរបស់ពួកគេក្នុងការបង់ពន្ធដើម្បីទ្រទ្រង់សេដ្ឋកិច្ចនិងអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែរីកចម្រើនដែលធ្វើឱ្យរដ្ឋាភិបាលមានចំណូលគ្រប់គ្រាន់ក្នុងការចំណាយផ្សេងៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមការសន្និដ្ឋានខាងលើរួចមក ក្រុមរបស់នាងខ្ញុំបានសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំយុទ្ធសាស្ត្រដ៏ល្អ នៃការប្រមូលចំណូលយ៉ាងមានប្រសិទ្ធភាព រួមទាំងការយល់ដឹងនូវចំណេះដឹង និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ តាមរយៈការវិវត្តន៍នូវបច្ចេកវិទ្យាថ្មីៗដែលមានលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្រុមរបស់នាងខ្ញុំ សូមបង្ហាញនូវភាពគាំទ្រ និងលើកទឹកចិត្តដល់អគ្គនាយកដ្ឋានពន្ធដារក្នុងការបន្តបេសសកម្ម ឬសកម្មភាពរបស់ខ្លួនក្នុងការអភិវឌ្ឍន៍នូវវិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗនិងពង្រឹងនីតិវិធីនេះឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត។ ទន្ទឹមនឹងនេះផងដែរ អគ្គនាយកដ្ឋានពន្ធដារគួរតែកែលម្អនូវចំណុចខ្វះខាតខ្លះៗដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែបន្ត និងបន្ថែមការផ្សព្វផ្សាយអំពីនីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈឱ្យកាន់តែទូលំទូលាយជូនអ្នកជាប់ពន្ធក៏ដូចជាប្រជាពលរដ្ឋទូទៅដើម្បីឱ្យពួកគាត់យល់ដឹងកាន់តែច្បាស់អំពីការរៀបចំសំណុំឯកសារសម្រាប់ការប្រកាសពន្ធឱ្យបានឆាប់រហ័ស និងមានភាពងាយស្រួល។

- ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថា គួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែពន្យល់និងផ្តល់ព័ត៌មានឱ្យកាន់តែច្បាស់អំពីតួនាទី និងភារកិច្ចរបស់អ្នកជាប់ពន្ធក្នុងការបង់ប្រាក់ពន្ធជូនរដ្ឋព្រោះរាល់ការបង់ប្រាក់ពន្ធទាំងអស់នោះជាប្រភពចំណូលដ៏សំខាន់ដែលរដ្ឋយកទៅបំភ្លឺទីសាធារណៈ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើសិក្ខាសិលាឱ្យបានច្រើនដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធ ឬសហគ្រាសឱ្យបានយល់ច្បាស់អំពីដំណើរការនៃការបង់ពន្ធ និងវិធីសាស្ត្រនៃការគណនាពន្ធឱ្យបានត្រឹមត្រូវជូនរដ្ឋ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើការផ្សព្វផ្សាយអំពីច្បាប់ បទប្បញ្ញត្តិ និងសេវានានាឱ្យកាន់តែច្បាស់លាស់និងទូលំទូលាយទៅកាន់សាធារណៈជនទាំងអស់តាមរយៈប្រព័ន្ធ Online និងមធ្យោបាយផ្សេងៗដែរងាយស្រួលដល់អ្នកជាប់ពន្ធ ។
- រាល់ចំណូលដែលប្រមូលបានពីអាករបំភ្លឺសាធារណៈអគ្គនាយកដ្ឋានពន្ធដារគួរតែបន្ថែមការដាក់ភ្លើងបំភ្លឺនៅតាមទីជនបទដាច់ស្រយាលដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណៈជន។

# ឯកសារយោង

# ឯកសារយោង

ស្តីពីប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ

- https://www.facebook.com/100064079683016/posts/1609497449303329/

ស្តីពីចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

- https://www.bakc.org.kh

ស្តីពីបេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

- https://km.m.wikipedia.org/wiki

ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ

- https://search.yahoo.com/search?fr=mcafee&type=E210US885G91826&p

ស្តីពីតួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

- https://gs.mef.gov.kh/contents

ស្តីពីការកំណត់គោលនយោបាយនិងនីតិវិធីនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈ

- https://m.freshnewsasia.com/index.php/en/freshnewsplus/320555-2023-12-10-05-53-37.html

ស្តីពីការគណនាអាករបំភ្លឺសាធារណៈ

- http://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf

ស្តីពីការប្រមូលអាករ

- https://www.bakc.org.kh/images/post/%E1%9E%9A%E1%9E%B6%E

ស្តីពីការទទួលលិខិតប្រកាស

- https://huskyandpartners.com/images/Law%20Library/Taxation/Other/20190509-Instruction%20on%20Tax%20Declaration%20Filing_2016_Kh.pdf.pdf

ស្តីពីការប្រមូលអាករដែលផ្តល់ប្រយោជន៍ដល់សង្គមជាតិ

- https://gs.mef.gov.kh/contents/uploads/2021/09/8%E1%9E%96%E1%9E%93%E1%9F%92%E1%9E%92%E1%9E%8A%E1%9E%B6%E1%9E%9A.pdf
- បណ្ណាល័យវិទ្យាស្ថានវ៉ាន់ដា ដែលដកស្រង់ចេញពីសៀវភៅសិស្សច្បង

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ




## ១-ទស្សនទាននៃចំណូលពន្ធផ្ទៃក្នុង

### ភាពខុសគ្នានៃកត្តាគន្លឹះសំខាន់ៗសម្រាប់ការប្រមូលពន្ធ រវាងប្រទេសអភិវឌ្ឍន៍ និងកម្ពុជា

| ល.រ | បរិយាយ | ប្រទេសអភិវឌ្ឍន៍ | ប្រទេសកម្ពុជា |
|---|---|---|---|
| ១ | ធនធានមនុស្ស | មានចំនួនច្រើន និង គុណភាពខ្ពស់ | មានចំនួនតិច និង គុណភាពមានកម្រិត |
| ២ | កម្រិតអនុលោមភាពសារពើពន្ធ របស់អ្នកជាប់ពន្ធ | ខ្ពស់ (អូស្រ្តាលី/ស៊ុយអែត៖ លើសពី ៩៥%) | ទាប |
| ៣ | ផ្នត់គំនិតនិងវប្បធម៌បង់ពន្ធ | កម្រិតខ្ពស់ | មានកម្រិត |
| ៤ | សមត្ថភាពក្នុងការកំណត់ហានិភ័យ | មានកម្រិតខ្ពស់ | មានកម្រិត |
| ៥ | កម្រិតនៃការគេចវេះពន្ធ | មានកម្រិតទាប | មានកម្រិតខ្ពស់ |
| ៦ | ប្រព័ន្ធពន្ធដារ | អភិវឌ្ឍល្អ | កំពុងកែទម្រង់ |
| ៧ | សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធ | មានសិទ្ធិអំណាចទូលំទូលាយ | កំពុងពង្រឹង |
| ៨ | បច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (IT & Infrastructure) | មានកម្រិតខ្ពស់ | បាននិងកំពុងបន្តអភិវឌ្ឍ |


២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ(២០១៩-២០២៣)
យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤
(Rectangular Strategy Phase4)
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
(PFMRP)
យុទ្ធសាស្ត្រគៀរចំណូល ២០១៩-២០២៣
(RMS)
ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ
(SP & OP)
អភិបាលកិច្ចល្អ
(Good Governance)
រដ្ឋបាលកិច្ចល្អ
(Good Administration)
ប្រសិទ្ធិភាពនៃភាពជាអ្នកដឹកនាំ
(Effective Leadership & Management)
គុណធិបតេយ្យ
(Meritocracy)
គោលបំណងជាយុទ្ធសាស្ត្រ៖
➢ គោលបំណងទី១៖ បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព
➢ គោលបំណងទី២៖បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ
➢ គោលបំណងទី៣៖ អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន


២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ
(១) តម្លាភាព
(Transparency)
(២) គណនេយ្យភាព
(Accountability)
(៣) ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព
(Effectivenessand Eficiency)
(Participation)
(៥) នីតិរដ្ឋ
(Rule of law)
(៦) សមធម៌ និង បរិយាប័ន្ន
(Equity and Incluseveness)
(៧) ការស្រុះស្រួលគ្នា
(Consensus orientated)
(Responsiveness)
អភិបាលកិច្ចល្អ
(Good Governance)

## ៣- លទ្ធផលនៃកំណែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ
### ប្រភេទពន្ធ និងអាករផ្សេងៗ

1. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ( 1% )
2. ពន្ធអប្បបរមា ( 1% )
3. អាករពិសេសលើទំនិញ និងសេវាមួយចំនួន ( 35 % ស្រា 30% ស្រាបៀ, 20% បារី, សំបុត្រយន្តហោះ 10%, ទូរគមនាគមន៍ 3% )
3. អាករបំភ្លឺសាធារណៈ ( 3% )
4. អាករលើការស្នាក់នៅ ( 2% )
5. ពន្ធកាត់ទុក ( ការជួល 10%, សេវាកម្ម និង Royalties 15%, ការប្រាក់ 15% ( កម្ចីក្នុងស្រុក ), ការប្រាក់ 4% ឬ 6% ( ស្ថាប័នហិរញ្ញវត្ថុ ) )
6. ពន្ធលើប្រាក់ចំណូល ( 20% )
7. ពន្ធប៉ាតង់ ( តូច- 100$, មធ្យម- 300$, ធំ 750$ ឬ 1,250$ )
8. ពន្ធលើស្លាកយីហោ
9. អាករលើតម្លៃបន្ថែម ( 10% )
10. ពន្ធលើប្រាក់បៀវត្ស ( 0% ដល់ 20% )
11. ពន្ធលើអចលនទ្រព្យ ( 0.1% )
12. ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ( 2% )
13. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
14. ពន្ធប្រថាប់ត្រា
    - ៤ % លើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ( ប្រកាសកំណត់តម្លៃអចលនទ្រព្យ )
    - 0.១ % លើតម្លៃភាគហ៊ុន ឬតម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាប្រើប្រាស់ថវិការដ្ឋ
    - ២៥០$ ចំពោះលិខិតមានលក្ខណគតិយុត្ត ៣ ប្រភេទ (លិខិតស្តីពីការបង្កើតក្រុមហ៊ុន, បិទក្រុមហ៊ុន និងរំលាយក្រុមហ៊ុន)

## ៣- លទ្ធផលនៃកំណែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ
### កំណែទម្រង់រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ




1) ន.រដ្ឋបាល និងកិច្ចការទូទៅ
2) ន.ហិរញ្ញវត្ថុ និងបុគ្គលិក
3) ន.នីតិកម្ម គោលនយោបាយសារពើពន្ធ
4) ន.ពន្ធចលនទ្រព្យ និងអចលនទ្រព្យ
5) ន.បច្ចេកវិទ្យាព័ត៌មាន
6) ន.ស៊ើបអង្កេតបទល្មើសពន្ធដារ
7) ន.គ្រប់គ្រងអ្នកជាប់ពន្ធធំ
8) ន.គ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
9) ន.សវនកម្មសហគ្រាស
10) សាលាពន្ធដារជាតិ
11) ទីចាត់ការពន្ធដាររាជធានីភ្នំពេញ




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 2,962.13 | 3,525.48 | 4,251.16 | 5,196.80 | 5,988.71 | 7,754.81 | 8,791.40 | 11,277.32 | 11,700.52 | 11,266.79 | 13,993.20 | 14,629.10 |
| ចំណូល (លានដុល្លារ) | $590.01 | $731.30 | $870.40 | $1,049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,197.85 | $2,819.33 | $2,869.02 | $2,781.92 | $3,455.11 | $3,612.12 |
| ផែនការ (ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 | 14,465.39 |
| ផែនការ (លានដុល្លារ) | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,268.41 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 |
| %ភាគរយនៃចំណូល | 88.88% | 100.60% | 101.80% | 106.94% | 111.53% | 105.32% | 113.00% | 114.27% | 123.20% | 101.36% | 124.02% | 122.54% | 101.13% |




VANDA


VANDA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...១២៨.....សហវ.[illegible]

# ប្រកាស
# ស្តីពី
# អាករសម្រាប់បំភ្លឺសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរា មេរ៉យ ឬថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ផលិតផលជាប់អាករ សំដៅដល់ សុរា មេរ៉យ ឬថ្នាំជក់។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- សុរា សំដៅដល់ ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល លើកលែងតែផលិតផលអាល់កុលដែលប្រើក្នុងវិស័យវេជ្ជសាស្ត្រ។

ខ- មេរ៉យ សំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ មានជាអាទិ៍ ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹង លើកលែងតែទឹកត្នោតជូរ និងស្រាស ដែលផលិតដោយមិនមានការកែច្នៃរក្សាគុណភាព និង/ឬវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម។

គ- ថ្នាំជក់ សំដៅដល់ផលិតផលទាំងមូលឬមួយផ្នែកដែលផ្សំឡើងដោយស្លឹកថ្នាំជក់ ឬសារធាតុថ្នាំជក់ ឬសារធាតុផ្សេងៗទៀតជាវត្ថុធាតុដើម ដែលផលិតសម្រាប់យកទៅជក់ មានជាអាទិ៍ បារី បារីស៊ីហ្គា និងបារីអេឡិចត្រូនិកគ្រប់ប្រភេទ។

២-អាករ សំដៅដល់ អាករសម្រាប់បំភ្លឺសាធារណៈ។

៣-បុគ្គលជាប់អាករ សំដៅដល់ អ្នកផលិត ឬអ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- អ្នកផលិត សំដៅដល់ ម្ចាស់ផលិតផលដែលផលិតផលិតផលជាប់អាករដោយខ្លួនឯង ឬដែលជួលបុគ្គលដទៃទៀតឱ្យផលិតផលិតផលជាប់អាករឱ្យខ្លួន។

ខ- អ្នកនាំចូល សំដៅដល់ ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬដែលប្រគល់សិទ្ធិឱ្យបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករឱ្យខ្លួន។

**ប្រការ៤ .-**

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់តាមអត្រា ៥ (ប្រាំ) ភាគរយ នៃមូលដ្ឋានគិតអាករ។

**ប្រការ៥ .-**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។

**ប្រការ៦ .-**

១- អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវដល់កំណត់និងត្រូវបង់តែម្តងគត់នៅពេលផ្គត់ផ្គង់ផលិតផលជាប់អាករដំបូងបន្ទាប់ពីផលិត ឬនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការផ្គត់ផ្គង់ផលិតផលជាប់អាករ ដែលកែច្នៃពីផលិតផលដែលបានបង់អាករសម្រាប់បំភ្លឺសាធារណៈរួចហើយ ត្រូវចាត់ទុកថាជាការផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត។

៣-វិធាននៃការផ្គត់ផ្គង់ ត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤ នៃមាត្រា៦១ នៃច្បាប់ស្តីពីសារពើពន្ធ។